**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# យន្តការថ្មីក្នុងការគ្រប់គ្រងរដ្ឋបាលដែនដី

# (ក្រុង ស្រុក ខណ្ឌ)

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមិនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ហៀម ឈុនធីរម្យ**

កញ្ញា **អ៊ុំ មរកត**

សាស្ត្រាចារ្យណែនាំ

សាស្ត្រាចារ្យ **ហៀង សាង**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៣

ឆ្នាំសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរឈ្មោះ **ហៀម ឈុនភីម្យ** និង **អ៊ុំ មរកត** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ឆ្នាំទី ៤ ជំនាន់ទី១៣ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា២០១៦ -២០២០។

## យើងខ្ញុំសូមថ្លែងអំណរគុណ និងសម្តែងការដឹងគុណយ៉ាងខ្ពង់ខ្ពស់ ព្រមទាំងកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះ

- លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា យើងខ្ញុំឱ្យធំដឹងក្តី ផ្តល់នូវដំបូន្មានល្អៗ ព្រមទាំងទំនុកបម្រុងការសិក្សារហូតមកដល់សព្វថ្ងៃនេះ។ បន្ថែមពីនេះទៀត ក៏សូមថ្លែងអំណរគុណដល់ លោកតា លោកយាយ និងសមាជិកក្រុមគ្រួសារ ដែលបានផ្តល់ជាកម្លាំងចិត្តដល់យើងខ្ញុំទាំងពីរ។
- ឯកឧត្តម **បណ្ឌិត លុយ ចណ្ណា** ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគណៈគ្រប់គ្រង **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់ឱកាសឱ្យយើងខ្ញុំទាំងអស់បានសិក្សារៀនសូត្រនៅទីនេះ។
- សូមថ្លែងអំណរគុណចំពោះលោកគ្រូសាស្ត្រាចារ្យណែនាំ **ហៀង សាង** ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការណែនាំ និងផ្តល់ជាគំនិតក្នុងការតាក់តែង ព្រមការស្រាវជ្រាវដោយមិនខ្លាចការនឿយហត់ ជួយបំពេញនូវចំនុចខ្វះខាត ដាស់តឿន ស្មារតី និងជំរុញទឹកចិត្តក្នុងការស្រាវជ្រាវឯកសារនេះឡើង។
- លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ច ដែលបានបង្រៀន អប់រំ និងណែនាំដល់យើងខ្ញុំ ដើម្បីជាស្ពានក្នុងការត្រិះរិះពិចារណា អភិវឌ្ឍន៍ខ្លួនឯង និងវិភាគនូវចំនុចល្អ អាក្រក់ និងជាពិសេសចំណេះដឹង និងជំនាញខ្លះៗជាដើមទុនក្នុងការអនុវត្តក្នុងសង្គមការងារ។
- ឯកឧត្តម **ង៉ាន់ ចំរើន** ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- ឯកឧត្តម **ចាន់ សុធា** ជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- លោក **ជ័យ សម្បត្តិផល្លា** ជាប្រធានអង្គភាពវិភាគ និងអភិវឌ្ឍគោលនយោបាយនៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរ សូមប្រសិទ្ធិពរជ័យដល់លោកអ្នកដែលមានគុណខាងលើទាំងអស់ ឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ជារដ្ឋបាលថ្នាក់ក្រោមជាតិដែលមានភាពមមាញឹក និងមានសម្ពុះខ្លាំង ដោយការស្ថិតនៅជិតប្រជាពលរដ្ឋ។ ដូច្នេះហើយ នៅចុងឆ្នាំ២០១៩ រដ្ឋាភិបាលកម្ពុជាបានដាក់ចេញ ការកែទម្រង់រចនាសម្ពន្ធរដ្ឋបាលថ្នាក់ក្រោមជាតិមួយ។ យន្តការនេះ ជាសមិទ្ធផលថ្មីរបស់រដ្ឋាភិបាលកម្ពុជា ដែលកើតចេញពីកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់ស្នូលទាំងបីរួមមានដូចជា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការគាំទ្រ និងការចូលរួមយ៉ាងសកម្មរបស់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ហេតុនេះហើយ ក្រុមយើងខ្ញុំបានលើកយកប្រធានបទ " **យន្តការថ្មីក្នុងការគ្រប់គ្រងរដ្ឋបាលដែនដី** ( **ក្រុង ស្រុក ខណ្ឌ** )" មកសិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារនេះឡើង ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីកំណែទម្រង់រចនាសម្ពន្ធរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ដំណើរការ ច្បាប់ មូលហេតុនៃកំណែទម្រង់ គោលបំណង និងអត្ថប្រយោជន៍របស់កំណែទម្រង់មួយនេះ។

នៅក្នុងការសិក្សាស្រាវជ្រាវឯកសារនេះឡើង យើងខ្ញុំទាំងពីរនាក់បានខិតខំសិក្សា និងស្រាវជ្រាវប្រមូលឯកសារពាក់ព័ន្ធផ្សេងៗជាច្រើនមានដូចជា រដ្ឋធម្មនុញ្ញ អនុក្រឹត្យរបស់រដ្ឋាភិបាល សៀវភៅច្បាប់ផ្សេងៗ និងការពិគ្រោះយោបល់ជាមួយលោកគ្រូសាស្ត្រាចារ្យណែនាំ ព្រមទាំងការចុះសម្ភាសន៍ផ្ទាល់ជាមួយមន្ត្រីជំនាញ ក្នុងការស្វែងរកទិន្នន័យដែលជាក់លាក់ និងច្បាស់លាស់ ដើម្បីបង្កើតជាសារណាបញ្ចប់ការសិក្សានេះឡើង។ យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សាមួយនេះ នឹងក្លាយជាចំណែកតូចមួយសម្រាប់បម្រើក្នុងវិស័យអប់រំ និងជាឯកសារជំនួយស្មារតីដល់សិស្ស និស្សិតជំនាន់ ជាពិសេសបម្រើដល់សិស្ស និស្សិត ដែលចូលចិត្តស្រាវជ្រាវ និងសិក្សាស្វែងយល់ ។

ដោយហេតុថា កិច្ចការស្រាវជ្រាវមួយនេះអាចនឹងមាននូវ ចំណុចខ្វះខាត មិនទាន់គ្រប់ជ្រុងជ្រោយ ឬមានការលើសលុសត្រង់ចំណុចណាមួយនៅក្នុងការប្រើប្រាស់ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លាឃ្លោង ការរៀបរៀងដោយប្រការណាមួយដោយអចេតនា។

ជាចុងក្រោយ សូមអធ្យាស្រ័យ និងខន្តីអភ័យទោសរាល់កំហុសឆ្គងទាំងឡាយដែលមាននៅក្នុងកិច្ចការមួយនេះ ហើយយើងខ្ញុំសូមស្វាគមន៍រាល់មតិរិះគន់ទាំងឡាយពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តនិស្សិតទាំងអស់ផងដែរ ដែលបានចូលរួមកែតម្រូវនូវចំណុចខ្វះខាត ក៏ដូចជាញ៉ាំងឱ្យមានការសិក្សាស្រាវជ្រាវនេះកាន់តែមានភាពច្បាស់លាស់ទាំងខ្លឹមសារ និងកាន់តែមានអត្ថន័យ។

# មាតិកា


ទំព័រ

**បញ្ជីអក្សរកាត់** ........ iv

**បញ្ជីតារាង** ........ v

**សេចក្ដីផ្ដើម** ........ ១

**១. លំនាំបញ្ហានៃការស្រាវជ្រាវ** ........ ១

**២. ចំណោទបញ្ហានៃការស្រាវជ្រាវ** ........ ២

**៣. គោលបំណងនៃការស្រាវជ្រាវ** ........ ៣

**៤. សារៈសំខាន់នៃការស្រាវជ្រាវ** ........ ៤

**៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ** ........ ៥

**៦. វិធីសាស្ត្រស្រាវជ្រាវ** ........ ៥

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........ ៦

**ជំពូកទី១**

**រំលឹកទ្រឹស្ដី**

**១.១ រដ្ឋបាលថ្នាក់ក្រោមជាតិ** ........ ៧

**១.២ ការគ្រប់គ្រងតាមបែបវិមជ្ឈការ** ........ ៧

**១.៣ ការគ្រប់គ្រងតាមបែបវិសហមជ្ឈការ** ........ ៨

**១.៤ ការគ្រប់គ្រងតាមបែបសហគ្គិនភាព** ........ ៩

**១.៥ អភិបាលកិច្ចល្អ** ........ ៩

១.៥.១ ការចូលរួម ........ ៩

១.៥.២ នីតិរដ្ឋ ........ ១០

១.៥.៣ តម្លាភាព ........ ១១

១.៥.៤ ការព្រមព្រៀងឯកភាពគ្នា ........ ១១

១.៥.៥ សមធម៌ ........ ១១

១.៥.៦ ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ........ ១១

១.៥.៧ គណនេយ្យភាព ........ ១២

១.៥.៨ ការឆ្លើយតប ........ ១២

១.៥.៩ ចក្ខុវិស័យជាយុទ្ធសាស្ត្រ ........ ១២

**១.៦ ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ** ........ ១៣

**១.៧ រដ្ឋបាលឯកភាព** ........ ១៣

**១.៨ គណនេយ្យភាព** ........ ១៤
**១.៩ ក្រុមប្រឹក្សា** ........ ១៤
**១.១០ គណៈអភិបាល** ........ ១៤
**១.១១ នាយករដ្ឋបាល** ........ ១៤

## ជំពូកទី២

## ស្ថានភាពទូទៅ

**២.១ សម័យសង្គមរាស្ត្រនិយម** ........ **១៦**
២.១.១ ការបែងចែកដែនដី ........ ១៦
២.១.២ ការគ្រប់គ្រងរដ្ឋបាលដែនដី ........ ១៦
**២.២ សម័យសាធារណរដ្ឋខ្មែរ** ........ ១៨
**២.៣ សម័យកម្ពុជាប្រជាធិបតេយ្យ** ........ ១៨
**២.៤ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា** ........ ១៩
**២.៥ សម័យព្រះរាជាណាចក្រកម្ពុជា** ........ ២០
២.៥.១ អំពីរាជធានី ខេត្ត ក្រុង ........ ២១
២.៥.២ អំពីស្រុក ខណ្ឌ ........ ២២
២.៥.៣ អំពីឃុំ សង្កាត់ ........ ២៤

## ជំពូកទី៣

## របកគំហើញនៃយន្តការថ្មីក្នុងការគ្រប់គ្រងរដ្ឋបាលដែនដី (ក្រុង ស្រុក ខណ្ឌ)

**៣.១ ក្រុមប្រឹក្សា** ........ ២៦
៣.១.១ តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា ........ ២៦
៣.១.២ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា ........ ២៦
៣.១.៣ ការជ្រើសរើសក្រុមប្រឹក្សា ........ ២៧
៣.១.៤ លក្ខណសម្បត្តិ ........ ២៧
៣.១.៥ ការបាត់បង់សមាជិកភាព ........ ២៧
**៣.២ គណៈអភិបាល** ........ ២៨
៣.២.១ តួនាទីនិងភារកិច្ចរបស់គណៈអភិបាល ........ ២៨
៣.២.២ សិទ្ធិអំណាចរបស់គណៈអភិបាល ........ ២៩
៣.២.៣ ការជ្រើសរើសគណៈអភិបាល ........ ២៩
៣.២.៤ លក្ខណសម្បត្តិ ........ ២៩
**៣.៣ នាយករដ្ឋបាល** ........ ៣០

៣.៣.១ ការតែងតាំងនាយករដ្ឋបាល.......... ៣០
៣.៣.២ តួនាទី និងភារកិច្ចរបស់នាយករដ្ឋបាល.......... ៣០
**៣.៤ អង្គភាពរបស់ក្រុមប្រឹក្សា**.......... ៣២
៣.៤.១ ការិយាល័យនិងអង្គភាពចំណុះទាំង៥ របស់ក្រុង ស្រុក ខណ្ឌ និងការិយាល័យជំនាញទាំង២០ ៣២
៣.៤.២ ការិយាល័យទាំង១៣ ក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ.......... ៣៣
**៣.៥ បុគ្គលិក**.......... ៣៦

**ជំពូកទី៤**

**បញ្ហាប្រឈម និងដំណោះស្រាយ**

**៤.១ បញ្ហាប្រឈម**.......... ៣៧
**៤.២ ដំណោះស្រាយ**.......... ៣៨
**សេចក្តីសន្និដ្ឋាន**.......... ៤០
**អនុសាសន៍**.......... ៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- **គ.ជ.អ.ប** ៖ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# បញ្ជីតារាង

តារាងទី ១ ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបាលរាជធានី-ខេត្ត-ក្រុង ....................២១
តារាងទី ២ ៖ រដ្ឋបាលស្រុក-ខណ្ឌ ....................២៣
តារាងទី ៣ ៖ រចនាសម្ព័ន្ធរដ្ឋបាលឃុំ-សង្កាត់ ....................២៤
តារាងទី ៤ ៖ រចនាសម្ព័ន្ធនៃរដ្ឋបាលព្រះរាជាណាចក្រកម្ពុជា ....................២៥
តារាងទី ៥ ៖ រចនាសម្ព័ន្ធរដ្ឋបាលក្រុង-ស្រុក ....................៣៤
តារាងទី ៦ ៖ រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ ....................៣៥

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ ត្រូវបានប្រទេសជាតិមួយចំនួនធំក្នុងពិភពលោកទទួលស្គាល់ថា ជាកត្តាមួយដែលជំរុញឱ្យប្រទេសជាតិមានការរីកចម្រើនប្រកបដោយចីរភាព។ ដោយហេតុថា ការគ្រប់គ្រងប្រភេទនេះ បានផ្តល់ឱកាសទៅដល់រាស្ត្រប្រជាគ្រប់រូបក្នុងការចូលរួមកសាងប្រទេសជាតិរួមគ្នា និងការពារនូវផលប្រយោជន៍រួម ដែលស្តែងចេញតាមរយៈការបោះឆ្នោតជ្រើសរើសអ្នកដំណាងដើម្បីការពារផលប្រយោជន៍ របស់ពួកគេ។ ដូចនេះហើយ បច្ចុប្បន្នគេអាចសម្គាល់ប្រទេសមួយថាជាប្រទេសដែលប្រកាន់នូវរបបប្រជាធិបតេយ្យ ដោយសារតែក្នុងប្រទេសនោះមានការបោះឆ្នោតជ្រើសរើសអ្នកកាន់អំណាច ដើម្បីបម្រើផលប្រយោជន៍រួម។ ជាក់ស្តែង វត្តមានលទ្ធិប្រជាធិបតេយ្យមានរយៈពេលជាយូរណាស់មកហើយ ដោយគិតចាប់ពីពេលដែលមនុស្សជាតិចាប់ផ្តើមរស់នៅជាមួយគ្នាជាកុលសម្ពន្ធដែលក្នុងនោះធ្វើការជ្រើសរើសក្នុងចំណោមញាតិព័ន្ធរបស់ខ្លួន។ មិនតែប៉ុណ្ណោះ គេឃើញមានលិទ្ធិប្រជាធិបតេយ្យសុទ្ធសាធ កើតមានឡើងនៅក្នុងការគ្រប់គ្រងរបស់ អាតែន (Athena) នៅក្នុងប្រទេសក្រិច ដោយហេតុថារាល់ការសម្រេចចិត្តរបស់ប្រទេសត្រូវធ្វើឡើងតាមការសម្រេចចិត្តដែលចេញពីឆន្ទៈរបស់ប្រជាជនគ្រប់រូបនៅក្នុងប្រទេស តាមរយៈក្រុមប្រឹក្សាប្រធាន (The Council of Chiefs)[1]។ ក្រុមប្រឹក្សានេះហើយដែលជាមូលដ្ឋានគ្រឹះនៃការសម្គាល់ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ នៅតាមប្រទេសជាច្រើនក្នុងសកលលោក។ ក៏ប៉ុន្តែការវិវត្តរបបនយោបាយនៃប្រទេសនីមួយៗមានភាពខុសគ្នា ហើយរយៈពេលក៏ខុសគ្នាៗទៅតាមបរិបទក្នុងសង្គមរបស់ប្រទេសទាំងនោះ ដោយខ្លះនៅតែរក្សាការគ្រប់គ្រងប្រទេសរបស់ពួកគេតាមបែបសង្គមនិយម ខ្លះក៏វិវត្តន៍មករបបសេរីនិយម ឬតាមបែបលទ្ធិប្រជាធិបតេយ្យ។ ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យនេះទៀតសោតមានច្រើនរបៀប និងច្រើនទម្រង់ទៅតាមប្រភេទនៃរដ្ឋ (រដ្ឋទោល ឬរដ្ឋសហព័ន្ធ)។

ជាមួយគ្នានេះដែរ ប្រទេសកម្ពុជាយើងបានឆ្លងកាត់នូវរបបគ្រប់គ្រងជាច្រើន ដោយគ្រាន់តែរាប់បញ្ចូលរបបគ្រប់គ្រងក្រោយសម័យអាណានិគមបារាំង យើងឃើញថាការគ្រប់គ្រងប្រទេសកម្ពុជាមានការប្រែប្រួល និងវិវត្តន៍ជាច្រើនលើកច្រើនសារ ពីការគ្រប់គ្រងតាមបែបរាជានិយមផ្តាច់ការរហូតមកដល់មានការបោះឆ្នោត និងគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ។ យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជា[2] ប្រទេសកម្ពុជាប្រកាន់ខ្ជាប់នូវរបបប្រជាធិបតេយ្យអាស្រ័យពហុបក្ស ហើយប្រជាពលរដ្ឋប្រើប្រាស់អំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រដ្ឋាភិបាល និងតុលាការ។ ដូចគ្នានេះដែរ អំណាចនៃការគ្រប់គ្រងជាតិ គឺមិនមែនប្រមូលផ្តុំតែបុគ្គលតែម្នាក់ ឬស្ថាប័នណាមួយនោះទេ។ អំណាចត្រូវបានបែងចែកជា ៣គឺ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ មិនតែប៉ុណ្ណោះ កម្ពុជាក៏បានកំពុងនិងព្យាយាមក្នុងការធ្វើកំណែទម្រង់ និងអភិវឌ្ឍន៍

[1] Gillin, J. L. (១៩១៩). What is meant by democracy. The origin of democracy, ២៤(០៦), ៧០៤-៧១៤. ដកស្រង់ចេញពី https://www.jstor.org/stable/2764122

[2] *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.* (២០០៨). រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា. http://national-assembly.org.kh/group-article/11

រដ្ឋបាលរបស់ខ្លួនយ៉ាងស្វិតស្វាញ ចាប់តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ។ ដំណាក់កាលនៃការវិវត្តរដ្ឋបាលកម្ពុជា ត្រូវបានបែងចែកជា៣គឺៈ ដំណាក់កាលនៃការកសាងមូលដ្ឋានគ្រឹះ (១៥ឆ្នាំ ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩៣) ដំណាក់កាលនៃការអភិវឌ្ឍ (១៥ឆ្នាំ ពីឆ្នាំ១៩៩៣ដល់ឆ្នាំ២០០៨) និងដំណាក់កាលនៃការពង្រឹងប្រសិទ្ធភាព (ពីឆ្នាំ២០០៨ដល់បច្ចុប្បន្ន)។[3] មកទល់បច្ចុប្បន្ន កម្ពុជាបានប្រឹងប្រែងរៀបចំរដ្ឋបាលឱ្យមានភាពប្រសើរឡើង ដោយការបង្កើតឱ្យមានការបែងចែកអំណាច និងផ្ទេរអំណាចពីរដ្ឋបាលថ្នាក់ជាតិ (រាជធានី និងខេត្ត) មករដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រុង ស្រុក ខណ្ឌ) តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីជំរុញការកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព គេចាំបាច់ត្រូវការនូវប្រព័ន្ធអភិបាលកិច្ចល្អដែលការប្រតិបត្តិមាននូវតម្លាភាព គណនេយ្យភាព និងជំរុញឱ្យកិច្ចអភិវឌ្ឍន៍មូលដ្ឋាន និងការផ្តល់សេវាសាធារណៈ ដែលជាតម្រូវការរបស់ប្រជារាស្ត្រ។ មួយវិញទៀត ទំនើបកម្មនៃបច្ចេកវិទ្យាដែលរួមមាននូវប្រព័ន្ធអ៊ីនធើណែត និងព័ត៌មានវិទ្យា ដូចជាប្រព័ន្ធបណ្តាញសង្គមជាដើម បានជំរុញឱ្យការចូលរួមរបស់ប្រជាពលរដ្ឋក្នុងប្រទេសប្រជាធិបតេយ្យមួយចំនួនធំ មានឱកាសកាន់តែច្រើនដើម្បីចូលរួមយ៉ាងសស្រាក់សស្រាំ ក្នុងសកម្មភាពអភិវឌ្ឍន៍ក្នុងសង្គម។ ទាំងអស់នេះជាកត្តាមួយផ្នែក ដែលនាំឱ្យមានការវិវឌ្ឍនៃកំណែទម្រង់នៃការគ្រប់គ្រប់របស់រដ្ឋនីមួយៗ រួមបញ្ចូលទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ។ ជាក់ស្តែងដើម្បីឱ្យការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនក្នុងមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័ស កម្ពុជានៅតែបន្ត និងពង្រឹងនូវគុណភាពនៃការគ្រប់គ្រងរបស់ខ្លួនតាមបែបប្រជាធិបតេយ្យ តាមរយៈសហត្ថិភាពអំណាចរវាងវិមជ្ឈការ និងវិសហមជ្ឈការពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ។ ដំណាក់កាលដំបូងរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវការអនុវត្តនៅថ្នាក់ឃុំ/សង្កាត់។ ក្រោយពីការអនុវត្តសហត្ថិភាពនៅថ្នាក់ឃុំ/សង្កាត់ទទួលបានជោគជ័យ រាជរដ្ឋាភិបាលបានពង្រីកគោលនយោបាយរបស់ខ្លួនដើម្បីឱ្យមានក្រុមប្រឹក្សាផ្សេងទៀត ដែលត្រូវបោះឆ្នោតជ្រើសរើសឡើងនៅថ្នាក់ក្រោមជាតិ ដូចជានៅរាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ បន្ថែមទៀត[4]។

បើទោះបីជាដំណើរការសាកល្បងនៅថ្នាក់ឃុំសង្កាត់ទទួលបានជោគជ័យក៏ដោយ ក៏ការពង្រីកគោលនយោបាយទៅ បណ្តាថ្នាក់ក្រោមជាតិដទៃទៀត មិនអាចធានាថាការអនុវត្តនឹងទទួលបានភាពជោគជ័យទាំងស្រុងឡើយ ដោយហេតុថាទីតាំងភូមិសាស្ត្រ និងថវិកាមានភាពខុសគ្នាទៅតាមតំបន់។ ហេតុដូច្នេះហើយ អ្វីទៅជាយន្តការនៃការគ្រប់គ្រងរដ្ឋបាល ដើម្បីឱ្យការប្រព្រឹត្តទៅនៃការគ្រប់គ្រងនៅថ្នាក់ក្រោមជាតិភាពប្រសើរជាង

[3] សួង លាង ហៃ (២០១០). *ការវិវត្តនៃរដ្ឋបាលកម្ពុជា* (១៩៩៣-២០០៨) [និក្ខេបបទបណ្ឌិតវិទ្យាសាស្ត្រនយោបាយ]. មហាវិទ្យាល័យមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ.

[4] ហៀង សាង (២០១៧). *នីតិរដ្ឋបាលទូទៅ* (បោះពុម្ពលើកទី៤). ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា: ពាងពុម្ពស៊ីហេង.

មុន ក្នុងការលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រ ទៅតាមគោលដៅកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ? តើធ្វើដូចម្តេចដើម្បីធ្វើឱ្យរដ្ឋបាលដែនដីអាចទទួលបាននូវប្រសិទ្ធផល និងប្រសិទ្ធភាពតាមដែល ខ្លួនចង់បាន? តើដំណើរការនៃយន្តការថ្មីក្នុងការគ្រប់គ្រងមានយ៉ាងដូចម្តេចខ្លះ? តើការអនុវត្តនេះជួបប្រទះនូវ ឧបសគ្គអ្វីខ្លះ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

បានជាក្រុមរបស់យើងជ្រើសរើសយកប្រធានបទ << **យន្តការថ្មីក្នុងការគ្រប់គ្រងរដ្ឋបាលដែនដី (ក្រុង ស្រុក ខណ្ឌ)** >> មកសិក្សាស្រាវជ្រាវ ដោយហេតុថាពួកយើងមានគោលបំណងដូចខាងក្រោម៖

ទី១ ការជឿនលឿននៃបច្ចេកវិទ្យា ព្រមទាំងការរីកសាយភាយនៃសាកលភាវូបនីយកម្ម បានធ្វើឱ្យ បរិបទសង្គម មានការវិវត្តយ៉ាងឆាប់រហ័ស ជាហេតុធ្វើឱ្យបទដ្ឋានគតិយុត្តត្រូវតែមានការផ្លាស់ប្តូរដើម្បីសម្របទៅ នឹងការវិវត្តនេះ។ ព័ត៌មានវិទ្យាជាដើម បានធ្វើឱ្យការចែកចាយព័ត៌មានពីបុគ្គលម្នាក់ៗមានភាពឆាប់រហ័សដែលជា ហេតុនាំឱ្យមានភាពវិជ្ជមាន និងអវិជ្ជមាន។ ក្នុងភាពវិជ្ជមាន គឺប្រជាពលរដ្ឋអាចទទួលដំណឹងយ៉ាងឆាប់រហ័ស និងអាចចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសង្គម។ ក្នុងភាពអវិជ្ជមាន គឺផ្តល់ឱកាសដល់ជនឆ្លៀតឱកាសមួយ ចំនួនប្រព្រឹត្តអំពើទុច្ចរិត។ ឧទាហរណ៍ ការចាប់ជំរិតតាមប្រព័ន្ធអ៊ីនធើណែត។ ហេតុដូចនេះហើយការវិវត្តនៃរដ្ឋ បាល ត្រូវតែមានភាពជឿនលឿនតាមទាន់បរិបទសង្គម។

ទី២ ការឆ្លើយតបរបស់រាជរដ្ឋាភិបាលមានសារៈសំខាន់ណាស់ទៅលើបញ្ហាខាងលើ។ មួយវិញទៀត ដោយសារកំណែទម្រង់រដ្ឋបាលដែនដីជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិកើនឡើងជាបន្តបន្ទាប់ ប្រធានបទរបស់ យើងមានគោលបំណងក្នុងការស្វែងយល់ពីដំណើរនៃការវិវត្តលើកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរាប់ ចាប់តាំងពីសម័យក្រោយអាណានិគមនិយមបារាំងមកដល់បច្ចុប្បន្ន។

ទី៣ រាល់ការដាក់ចេញនូវគោលនយោបាយនីមួយៗ តែងតែកើតមានឡើងនូវឧបសគ្គ ក្នុងពេលអនុវត្ត គោលនយោបាយ បើទោះបីជាកំណែទម្រង់ដែនដីនៅថ្នាក់ក្រោមជាតិធ្លាប់បានអនុវត្ត និងទទួលបានជោគជ័យ ក្នុងជំហានដំបូងនៅថ្នាក់ឃុំ/សង្កាត់ ក៏ដោយក្តីក៏ការពង្រីកការអនុវត្តសហគ្គិភាព នៅតាមក្រុង/ស្រុក/ខណ្ឌនៅតែ មានការលំបាក ដោយសារកត្តាទាំងឡាយដែលអាចកើតមានឡើងដូចជា ទីតាំងភូមិសាស្ត្រ ធនធានមនុស្ស សេដ្ឋកិច្ច និងមូលធនជាដើម។ ហេតុដូចនេះហើយ ប្រធានបទរបស់យើងមានគោលបំណងក្នុងការសិក្សាអំពី ឧបសគ្គ ដែលកើតមានឡើងក្នុងពេលគោលនយោបាយបានដាក់ចេញទៅតាមបណ្តារដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រុង/ស្រុក/ខណ្ឌ)។

ទី៤ ពួកយើងសង្ឃឹមថាការសិក្សាស្រាវជ្រាវរបស់យើង អាចជួយសម្រួលទៅដល់និស្សិត និងអ្នកអានឱ្យ កាន់តែច្បាស់អំពីការវិវត្តនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីជាការសិក្សានេះគ្រាន់តែផ្តោតតែនៅ

លើមួយជ្រុងនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ពួកយើងសង្ឃឹមថាការសិក្សានេះជាប្រទីបតូចមួយដែលអាចឱ្យនិស្សិតជំនាន់ក្រោយអាចស្រាវជ្រាវបន្ថែម និងពង្រីកន័យសេចក្តីនៃប្រធានបទឱ្យកាន់តែធំទូលាយបន្ថែមទៀត ព្រោះប្រទេសកម្ពុជាជាប្រទេសប្រជាធិបតេយ្យក្មេងខ្ចីនៅឡើយ ដូចនេះហើយការកែប្រែនឹងនូវតែបន្តថែមទៀត។ ការសិក្សាស្រាវជ្រាវអំពីប្រធានបទខាងលើពិតជាមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះប្រធានបទនេះនឹងអាចជាចំណែកមួយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋខ្មែរ ព្រមទាំងនិស្សិតជាច្រើនដែលកំពុងតែសិក្សានៅតាមបណ្តាសាកលវិទ្យាល័យផ្សេងៗ។ ចំណែកឯក្រុមរបស់ពួកខ្ញុំវិញ ប្រធានបទខាងលើពិតជាមានសារៈសំខាន់ ក៏ដោយសារតែការសិក្សារបស់និស្សិតផ្នែករដ្ឋបាលសាធារណៈភាគច្រើន ពុំទាន់មានការយល់ដឹងឱ្យបានស៊ីជម្រៅនៅឡើយអំពីប្រធានបទខាងលើ ទោះបីជាពួកយើងធ្លាប់បានសិក្សាពីមុនមក។ មួយវិញទៀត ប្រធានបទខាងលើជាប្រធានបទមួយដែលថ្មីសម្រាប់ពួកយើង ដូច្នេះហើយពួកយើងនឹងព្យាយាមស្វែងយល់លើប្រធានបទនេះ ឱ្យកាន់តែប្រសើរឡើង ហើយខិតខំស្វែងរកព័ត៌មាន ឯកសារដែលពាក់ព័ន្ធ និងទិន្នន័យដែលថ្មីបំផុតតាមដែលអាចធ្វើទៅបាន ដើម្បីជាស្ពានសម្រាប់និស្សិតដែលចង់សិក្សាលើប្រធានបទដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវរបស់ពួកយើងអាចសិក្សាឱ្យកាន់តែសុក្រឹត និងធំទូលាយជាងនេះទៅទៀត។

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាពីប្រធានបទរបស់យើងពិតជាមានសារៈសំខាន់ ផ្អែកទៅលើចំណុចមួយចំនួនដូចខាងក្រោម៖

- អ្នកអានគ្រប់រូបអាចដឹងឱ្យកាន់តែច្បាស់អំពីយន្តការថ្មីនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលសកម្មភាពទាំងអស់នេះសុទ្ធសឹងតែជាអ្វីដែលប្រជាជនគ្រប់រូបគួរតែដឹង។ ឧទាហរណ៍សេវាសាធារណៈដែលរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ផ្តល់ជូនប្រជាពលរដ្ឋរបស់ខ្លួនជាដើម និងការរក្សាសន្តិសុខក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម។ ទាំងអស់នេះជាកត្តា ដែលនាំឱ្យរាស្ត្រប្រជាយល់ដឹងពីសារៈសំខាន់របស់ខ្លួនក្នុងការចូលរួមសកម្មភាពសង្គម និងសារៈសំខាន់នៃការបោះឆ្នោតជ្រើសរើសអ្នកតំណាងមូលដ្ឋានរបស់ខ្លួន។
- បង្កើននូវទំនុកចិត្តរបស់ប្រជាពលរដ្ឋគ្រប់រូប លើការទទួលយកនូវសេវាសាធារណៈ។
- ការសិក្សាលើប្រធានបទនេះមានសារៈសំខាន់ដល់ពួកយើងផងដែរ ដោយហេតុថាការសិក្សាលើប្រធានបទនេះបានអនុញ្ញាតឱ្យយើងបានស្វែងយល់ពីខ្លឹមសារនៃប្រធានបទ និងព័ត៌មានបន្ថែមដែលបានមកពីការស្រាវជ្រាវ និងបានជាបទពិសោធន៍ក្នុងការសរសេរ និងបំណិនបន្ថែមនៅក្នុងជីវិត។ មួយវិញទៀតការសរសេរអត្ថបទសិក្សាស្រាវជ្រាវនេះ គឺជាគោលបំណងរបស់ពួកយើងតាំងពីថ្នាក់មូលដ្ឋានមកម្ល៉េះ ហេតុដូចនេះហើយ ការសរសេរនេះគឺមានអត្ថន័យយ៉ាងជ្រៀលជ្រៅសម្រាប់ពួកយើង ដោយមិនមែនត្រឹមតែជាកាតព្វកិច្ចក្នុងការបញ្ចប់ការសិក្សាប៉ុណ្ណោះទេ។

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដោយហេតុថាការសិក្សាទៅលើការវិវត្តនៃរដ្ឋបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានភាពធំទូលាយ ក៏ប៉ុន្តែពេលវេលារបស់ពួកយើង ព្រមទាំងបញ្ហាជំងឺរាតត្បាតកូរ៉ូណា (កូវីត១៩) បានធ្វើឱ្យពួកយើងបានកំណត់យកដែនកំណត់នៃការស្រាវជ្រាវត្រឹមរដ្ឋបាលដែនដីថ្នាក់ក្រោមជាតិ ក្រុង/ស្រុក/ខណ្ឌ និងគិតចាប់ពីសម័យក្រោយឯករាជ្យពីបារាំងរហូតដល់បច្ចុប្បន្ន ជាពិសេសក្រោយឆ្នាំ២០០៨។ ប្រធានបទនេះ នឹងផ្តោតសំខាន់លើចំណុចមួយចំនួនដូចជា៖

- ការវិវត្តនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិពីឆ្នាំ១៩៤៥ ដល់បច្ចុប្បន្ន។
- រចនាសម្ពន្ធ និងដែនសមត្ថកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ចំណុចអវិជ្ជមានក្រោយការអនុវត្តគោលនយោបាយសហត្ថិភាព។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីឱ្យលទ្ធផលនៃការស្រាវជ្រាវ ទទួលបាននូវលទ្ធផលអាចទទួលយកបានតាមបែបវិទ្យាសាស្ត្រ និងមានកម្រិតជឿជាក់ខ្ពស់ យើងនឹងយកនូវវិធីសាស្ត្រស្រាវជ្រាវមកប្រើប្រាស់ ដោយកម្រិតនៃការជឿជាក់នេះផ្អែកទៅលើទិន្នន័យ និងការវិភាគទិន្នន័យ។

***ការកំណត់អថេរ៖***

ជាដំបូងពួកយើងនឹងធ្វើការកំណត់អថេរ ដើម្បីកំណត់ទិសដៅស្វែងរកទិន្នន័យ ដោយអថេរត្រូវបានបែងចែកឡើងជាពីរគឺ អថេរឯករាជ្យ និងអថេរមិនឯករាជ្យ។

**<u>អថេរឯករាជ្យ</u>**៖ ច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងៗ ដែលទាក់ទងទៅនឹងការធ្វើសមាហរណកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ និងបទសម្ភាសន៍ជាមួយភ្នាក់ងារដែលពាក់ព័ន្ធ។

**<u>អថេរមិនឯករាជ្យ</u>**៖ សមាហរណកម្មរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលកម្ពុជាកំពុងជួបប្រទះ។

***ការប្រមូលទិន្នន័យ៖***

ការសិក្សាលើប្រធានបទនេះ នឹងប្រើប្រាស់នូវទិន្នន័យដែលមានស្រាប់យកមកវិភាគ។ ទិន្នន័យដែលយកមកសរសេរ និងប្រើប្រាស់ ត្រូវបានយកមកពីឯកសារបណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឯកសារដែលបានមកពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គេហទំព័រនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា Google-Scholar ជាដើម។

ការសិក្សាស្រាវជ្រាវនេះ ក៏នឹងមាននូវការប្រើប្រាស់នូវទិន្នន័យបឋមផងដែរ ដោយសារសម្ភាសន៍ដោយផ្ទាល់នូវមន្ត្រីរាជការ ដែលកំពុងបម្រើការនៅគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិផងដែរ។

***ការវិភាគទិន្នន័យៈ***

ទិន្នន័យដែលប្រមូលបាននឹងត្រូវយកមកវិភាគតាមបែបពណ៌នា ពីការផ្លាស់ប្តូរកែប្រែនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ មុខងារ ទំនាក់ទំនង រចនាសម្ពន្ធ ការជ្រើសតាំង ក្នុងឆ្នាំកន្លងមក។

## ៧. រចនាសម្ពន្ធនៃការស្រាវជ្រាវ

រចនាសម្ពន្ធនៃការសិក្សាលើប្រធានបទនេះ ត្រូវបានបែកចែកជា ២កថាខណ្ឌ និង ៤ជំពូក។

- សេចក្តីផ្តើម
- ជំពូកទី១ ៖ រំលឹកទ្រឹស្តី
- ជំពូកទី២ ៖ ការរៀបចំរដ្ឋបាលមុនពេលមានកំណែទម្រង់វិមជ្ឈការ
- ជំពូកទី៣ ៖ របកគំហើញនៃយន្តការថ្មីក្នុងការគ្រប់គ្រងរដ្ឋបាលដែនដី (ក្រុង ស្រុក ខណ្ឌ)
- ជំពូកទី៤ ៖ បញ្ហាប្រឈម និងដំណោះស្រាយ
- សេចក្តីសន្និដ្ឋាន

# ជំពូកទី១

# រំលឹកទ្រឹស្តី

## ១.១ រដ្ឋបាលថ្នាក់ក្រោមជាតិ

យោងតាមមាត្រា១៤៥ថ្មីនៃរដ្ឋធម្មនុញ្ញៈ ទឹកដីព្រះរាជាណាចក្រកម្ពុជាចែកចេញជាខេត្ត ក្រុង ស្រុក។ ខេត្តចែកចេញជាស្រុក ហើយស្រុកចែកជាឃុំ។ ក្រុងចែកជាខណ្ឌ ហើយខណ្ឌចែក ជាសង្កាត់។[5]

ចាប់ពីឆ្នាំ២០០៩មក រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើត និងជំរុញធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ បន្ថែមទៀតនោះ នៅក្នុងមាត្រា៤ និងមាត្រា៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានចែងបញ្ជាក់ថា មាត្រា៤ ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ រាជធានីភ្នំពេញ ចែកជាខណ្ឌ។ ខណ្ឌចែកជាសង្កាត់។ មាត្រា៥ ខេត្តចែកជា ក្រុង និង ជាស្រុក។ ក្រុងចែកជា សង្កាត់។ ស្រុកចែកជាឃុំ។[6] រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាល ខណ្ឌ រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដែលរដ្ឋបាលនីមួយៗមានក្រុមប្រឹក្សាមួយជាតំណាង។[7]

## ១.២ ការគ្រប់គ្រងតាមបែបវិមជ្ឈការ

វិមជ្ឈការគឺសំដៅទៅលើការផ្ទេរនូវមុខងារ និងធនធានមួយចំនួនរបស់រដ្ឋាភិបាល ទៅឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែលជាប់ឆ្នោតហើយក្រុមប្រឹក្សានេះ ត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ វិមជ្ឈការជាការផ្តល់នូវអំណាច និងឆន្ទានុសិទ្ធិពេញលេញដល់ក្រុមប្រឹក្សាដើម្បីធ្វើសេចក្តីសម្រេចចិត្ត ដែលឆ្លុះបញ្ចាំងពីសេចក្តីត្រូវការ ផលប្រយោជន៍ និងតថភាពនៅមូលដ្ឋាន។ ប៉ុន្តែអំណាច និងឆន្ទានុសិទ្ធិដែលក្រុមប្រឹក្សាទទួលបាន ត្រូវមានដែនកំណត់។[8]

**<u>ទី១</u>** វិមជ្ឈការ ត្រូវតែមានអាជ្ញាធរថ្នាក់ក្រោមជាតិមួយ ត្រូវបានបោះឆ្នោតជ្រើសរើសឡើង ដើម្បីជាមធ្យោបាយសម្រាប់អនុវត្តការងារ។ ជាគោលការណ៍ វិមជ្ឈការអាចអនុវត្តចំពោះរដ្ឋបាលនានានៅក្នុងថ្នាក់ក្រោមជាតិទាំងអស់ឲ្យតែរដ្ឋបាលទាំងនោះបោះឆ្នោតជ្រើសរើសឡើង។

**<u>ទី២</u>** វិមជ្ឈការ តម្រូវឱ្យរាជរដ្ឋាភិបាលលះបង់ និងផ្ទេរភាពជាម្ចាស់លើមុខងារសមស្របទៅឱ្យក្រុមប្រឹក្សាដែលជាប់ឆ្នោត។ មុខងារអាចមានអត្ថន័យច្រើនយ៉ាង។ មុខងារអាចជាសេវា ដែលផ្តល់ឱ្យប្រជាពលរដ្ឋ។ លើសពីនេះទៅទៀត ក៏មានមុខងារដែលទាក់ទងនឹងវិស័យនានាដូចជា មុខងារធ្វើផែនការរៀបចំថវិកា ការធ្វើលទ្ធកម្ម

---

[5] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣)

[6] គ្រូឧត្តមសិក្សាជាន់ខ្ពស់ ងឹយ ធឿន (២០១៧), *នីតិរដ្ឋបាល*

[7] *កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ* (២០១០-២០១៩)

[8] សាស្ត្រាចារ្យ ហៀង សាង (២០១៨), *សហគ្គិភាពរដ្ឋបាលដែនដីនៃកម្ពុជា*

ការត្រួតពិនិត្យ និងការវាយតម្លៃគ្រប់គ្រងបុគ្គលិក និងការចេញដីការជាដើម។ ជាគោលការណ៍ រាជរដ្ឋាភិបាលធ្វើការត្រួតពិនិត្យទៅលើមុខងារទាំងនោះ ដើម្បីធានាឱ្យបានថា តើសកម្មភាពអ្វីដែលផ្ទុយ ឬប្រឆាំងទៅនឹងផលប្រយោជន៍ជាតិ?

**ទី៣** នៅក្នុងវិមជ្ឈការ ក្រុមប្រឹក្សាជាប់ឆ្នោត ត្រូវតែទទួលបាននូវការផ្ទេរធនធានចាំបាច់ ដើម្បីសម្រេចអនុវត្ត និងគ្រប់គ្រងនូវមុខងាររបស់ខ្លួន។ ធនធានទាំងនោះរួមមានៈ ហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិចាំបាច់ដើម្បីអនុវត្តន៍នូវមុខងារនីមួយៗ។

វិមជ្ឈការគឺមានគោលបំណងផ្តល់នូវស្វ័យភាពមូលដ្ឋាន។ ប៉ុន្តែមិនមែនអធិបតេយ្យដល់ ក្រុមប្រឹក្សាជាប់ឆ្នោតធ្វើជាតំណាងឲ្យសហគមន៍មូលដ្ឋានរបស់ពួកគេ ហើយក្រុមប្រឹក្សានេះមាន ការឆ្លើយតប និងមានគណនេយ្យភាពចំពោះសហគមន៍មូកដ្ឋានរបស់ពួកគេ លើការអនុវត្តនូវមុខងាររបស់ខ្លួន។ វិមជ្ឈការមិនមានន័យថា ជាការផ្តាច់ក្រុមប្រឹក្សាពីថ្នាក់ក្រោមជាតិ ឬពីអង្គភាពរបស់ ថ្នាក់ ជាតិ ឬពីថ្នាក់ផ្សេងៗនោះទេ។ វិមជ្ឈការត្រូវបានកសាងឡើង ដោយផ្អែកទៅលើអភិក្រមដ៏រឹងមាំដើម្បីសម្របសម្រួល កិច្ចសហការគ្នា និងការពឹងផ្អែកលើគ្នាទៅវិញទៅមករវាងថ្នាក់អភិបាលកិច្ចផ្សេងៗ ប៉ុន្តែថ្នាក់នីមួយៗនៅតែមានស្វ័យភាពរៀងៗខ្លួននៅក្នុងការអនុវត្តអាណត្តិ និងមុខងាររបស់ខ្លួន។

## ១.៣ ការគ្រប់គ្រងតាមបែបវិសហមជ្ឈការ

វិសហមជ្ឈការ សំដៅទៅលើការធ្វើប្រតិភូកម្មការងារពីថ្នាក់ជាតិទៅឲ្យអង្គភាពថ្នាក់ក្រោមជាតិដទៃទៀត។[9] ឬក៏ន័យមួយទៀត វិសហមជ្ឈការគឺជាបច្ចេកទេសគ្រប់គ្រងរដ្ឋបាលមួយ ដែលអាជ្ញាធររដ្ឋបាលកណ្តាលរំលែកកិច្ចការមួយចំនួនទៅឲ្យអាជ្ញាធររដ្ឋបាលមូលដ្ឋានធ្វើការសម្រេចដោយខ្លួនឯងផ្ទាល់ តាមការកំណត់ហើយសម្រេចតាងនាមអាជ្ញាធររដ្ឋបាលកណ្តាល។

ដូច្នេះអាជ្ញាធរមូលដ្ឋាន ធ្វើការសម្រេចកិច្ចការចាំបាច់ និងបន្ទាន់ខ្លះៗនៅនឹងកន្លែង (មូលដ្ឋាន) ដោយមិនចាំបាច់សុំការអនុញ្ញាត ក្នុងការសម្រេចពីអាជ្ញាធររដ្ឋបាលកណ្តាលដូចមុនឡើយ ព្រោះអាជ្ញាធរមូលដ្ឋាននៅពេលនេះ ទទួលបានសិទ្ធិអំណាចក្នុងការសម្រេចតាមការកំណត់ឱ្យក្នុងលក្ខខណ្ឌដែលចែងច្បាស់លាស់ទៅហើយ។

ការគ្រប់គ្រងរដ្ឋបាលតាមប្រភេទនេះ គឺជាការគ្រប់គ្រងតាមឋានានុក្រមរដ្ឋបាលដែលអំណាចកណ្តាលបានផ្តល់ឱ្យរដ្ឋបាលក្រោមជាតិសម្រេចតាមលំដាប់ថ្នាក់រៀងៗខ្លួន។

ការរំលែកអំណាចកណ្តាលក្នុងការសម្រេចនេះ គេប្រើវិធីមួយហៅថាប្រតិភូកម្មដែលចែកចេញជាពីរគឺៈ

- **ប្រតិភូកម្មអំណាច** គឺជាការផ្ទេរសមត្ថកិច្ចមួយផ្នែកទៅឱ្យអាជ្ញាធររដ្ឋបាលទាំងឡាយ នៅក្នុង

[9] សាស្ត្រាចារ្យ ហៀង សាង និងអនុបណ្ឌិត ប៉េង ឆុង (២០១២), *ការគ្រប់គ្រងរដ្ឋបាលដែនដី*

ឋានានុក្រមរដ្ឋបាលរបស់ខ្លួនប៉ុណ្ណោះ។ ប្រតិភូកម្មអំណាចនេះធ្វើទៅបាន លុះត្រាតែមានលិខិតបទដ្ឋានគតិយុត្តចែងប៉ុណ្ណោះ។ ប្រតិភូកម្មមិនពុំអាចធ្វើតាមការនឹកឃើញ ហើយក៏ពុំអាចធ្វើទាំងស្រុងដែរ។

- **ប្រតិភូកម្មហត្ថលេខា** គឺជាវិធីមួយដែលតាមរយៈនេះ អាជ្ញាធររដ្ឋបាលនីមួយៗបានប្រគល់ទៅឱ្យសហការីណាម្នាក់របស់ខ្លួននូវការចុះហត្ថលេខាជំនួសលើសេចក្ដីសម្រេចខ្លះ ដែលនេះជាភាពងាយស្រួលមួយផ្នែកការងារគ្រប់គ្រងរដ្ឋបាល ដោយពុំចាំបាច់ធ្វើប្រតិភូកម្មអំណាចទៀតទេ។ សហការីនេះមិនអាចផ្ទេរការចុះហត្ថលេខាជំនួសទៅឱ្យជនទីបីបានឡើយ។ ប្រតិភូកម្មហត្ថលេខានេះ ត្រូវប្រគល់ឱ្យចំឈ្មោះបុគ្គលដែលជាសហការីដោយបញ្ជាក់ពីឋានៈ តួនាទីឲ្យបានច្បាស់លាស់ ហើយត្រូវធ្វើសាជាថ្មីបើមានការផ្លាស់ប្ដូរបុគ្គល។

ការធ្វើប្រតិភូកម្មហត្ថលេខា គឺមានតែលើការចុះហត្ថលេខាប៉ុណ្ណោះ ដោយគ្មានប៉ះពាល់ ដល់ការបែងចែកអំណាចទេ។ អាជ្ញាធរដែលផ្ទេរហត្ថលេខាអាចរក្សាសិទ្ធិចុះហត្ថលេខាវិញគ្រប់ពេលវេលា។[10]

## ១.៤ ការគ្រប់គ្រងតាមបែបសហគ្គិភាព

ដើម្បីបំពេញឲ្យគ្នាទៅវិញទៅមករវាងចំណុចខ្វះខាតវិមជ្ឈការនិងវិសហមជ្ឈការ គេមានរូបមន្តថ្មីមួយគឺធ្វើយ៉ាងណាឱ្យមានសហគ្គិភាពរវាងវិមជ្ឈការ និងវិសហមជ្ឈការ ដែលអំណាចរដ្ឋ និងអំណាចរាស្ត្រនៅជាមួយគ្នា និងជួយគ្នាទៅវិញទៅមក។ ការអនុវត្តបច្ចេកទេសវិសហមជ្ឈការ បានត្រឹមតែមានការតែងតាំងអាជ្ញាធរមូលដ្ឋានប៉ុណ្ណោះ ដោយពុំមានលក្ខណៈប្រជាធិបតេយ្យទេ។ ដើម្បីនាំប្រទេសជាតិដាក់ក្នុងសង្គមប្រជាធិបតេយ្យ អ្នកដឹកនាំរដ្ឋត្រូវចាប់យកប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការមកអនុវត្ត ពីព្រោះអាជ្ញាធរមូលដ្ឋានត្រូវបានបង្កើតឡើងដោយការបោះឆ្នោតពីប្រជាពលរដ្ឋក្នុងដែនដីមូលដ្ឋាននោះផ្ទាល់។[11]

## ១.៥ អភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ ត្រូវបានគេឲ្យនិយមន័យផ្សេងៗគ្នាអាស្រ័យនឹងស្ថានភាពជាក់ស្ដែង។ ជាសាមញ្ញអភិបាលកិច្ចល្អមានន័យថា "ជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រង សេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ"។

គោលការណ៍នៃអភិបាលកិច្ចល្អមាន៩ដូចខាងក្រោម៖

### ១.៥.១ <u>ការចូលរួម</u>

ការចូលរួមក្នុងបរិបទអភិបាលកិច្ចល្អ សំដៅទៅលើការចូលរួមរបស់ប្រជាពលរដ្ឋទាំងបុរស និងស្ត្រី

[10] គ្រូឧត្តមសិក្សាជាន់ខ្ពស់ ង៉ីយ ធឿន (២០១៧), *នីតិរដ្ឋបាល*

[11] គ្រូឧត្តមសិក្សាជាន់ខ្ពស់ ង៉ីយ ធឿន, *ប្រព័ន្ធរដ្ឋបាលកម្ពុជា*

(អាជ្ញាធរ ប្រជាពលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាលនានា និងអ្នកពាក់ព័ន្ធផ្សេងៗទៀត) ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តនោះ។ សារៈសំខាន់នៃការចូលរួម គឺដើម្បីធានាថាព័ត៌មានទាំងឡាយស្តីពីបញ្ហាតម្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋគ្រប់រូបត្រូវបានប្រមូល និងវិភាគបានគ្រប់ជ្រុងជ្រោយមុននឹងធ្វើការសម្រេចចិត្ត។

ការចូលរួមធ្វើឡើងតាមពីររបៀប គឺការចូលរួមដោយផ្ទាល់ និងការចូលរួមតាមរយៈអ្នកតំណាង។

**ក. ការចូលរួមដោយផ្ទាល់**

ការចូលរួមដោយផ្ទាល់ មានន័យថាជាការចូលរួមរបស់អ្នកពាក់ព័ន្ធគ្រប់រូបដោយខ្លួនឯង ផ្ទាល់នៅក្នុងដំណើរនៃការធញផើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តនោះ។ ក្នុងរបបប្រជាធិបតេយ្យ ប្រជាពលរដ្ឋ មានសិទ្ធិចូលរួមដោយផ្ទាល់ពាក់ព័ន្ធទៅនឹងកិច្ចការសាធារណៈ និងនៅក្នុងសកម្មភាពអភិវឌ្ឍមូលដ្ឋានដូចជា៖

- ការបោះឆ្នោត
- ការចូលរួមក្នុងគណបក្សនយោបាយ
- ការឈរឈ្មោះបោះឆ្នោត
- ការបង្កើតសមាគម សហគមន៍នានា
- ការចូលរួមនៅក្នុងដំណើរការ និងធ្វើសេចក្តីសម្រេចចិត្តនៅក្នុងការកសាងផែនការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។
- ការចូលរួមជាកម្លាំងពលកម្ម និងធនធានរបស់ប្រជាពលរដ្ឋ នៅក្នុងសកម្មភាពអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន ក៏ចាត់ទុកជាការចូលរួមដោយផ្ទាល់ដែរ។ ល។

**ខ. ការចូលរួមតាមរយៈអ្នកតំណាង**

ការចូលរួមតាមរយៈអ្នកតំណាង មានន័យថាអ្នកតំណាងរបស់ប្រជាពលរដ្ឋចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចនោះ។

អ្នកតំណាងប្រជាពលរដ្ឋ អាចត្រូវបានជ្រើសរើសតាមនីតិវិធីផ្សេងៗទៅតាមលក្ខណៈ និងស្ថានភាពជាក់ស្តែងដូចជា៖

- ការតែងតាំង ឬការជ្រើសរើសដោយមានការព្រមព្រៀងឯកភាពគ្នា។
- ការបោះឆ្នោតសកល ឬអសកល (សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់)។
- ទំនៀមទម្លាប់ប្រពៃណី។ល។

**១.៥.២ <u>នីតិរដ្ឋ</u>**

នីតិរដ្ឋក្នុងន័យអភិបាលកិច្ចល្អ ទាមទារឱ្យមានឯកសារក្របខណ្ឌច្បាប់គ្រប់គ្រាន់ដើម្បីបម្រើ និងការពារ

ផលប្រយោជន៍សាធារណៈ ការពារសិទ្ធិមនុស្ស ពិសេសក្រុមងាយរងគ្រោះ ឬក្រុមភាគតិច ហើយច្បាប់ទាំងនោះត្រូវបានអនុវត្តដោយមិនលម្អៀង។ លើសពីនេះទៀត ត្រូវមានប្រព័ន្ធទទួលខុសត្រូវ មានប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ និងសមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលម្អៀង និងមិនពុករលួយ។

នីតិរដ្ឋក្នុងន័យនេះ អភិបាលកិច្ចល្អផ្តោតសំខាន់ទៅលើ៖

- ឯកសារក្របខណ្ឌច្បាប់
- ការការពារសិទ្ធិមនុស្ស
- ប្រព័ន្ធទទួលខុសត្រូវ
- ប្រព័ន្ធយុត្តិធម៌
- សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលម្អៀង និងមិនពុករលួយ។

**១.៥.៣ តម្លាភាព**

តម្លាភាពក្នុងន័យអភិបាលកិច្ចល្អមានន័យថា រាល់ការសម្រេចចិត្ត និងការអនុវត្តសេចក្តី សម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តនោះ ត្រូវធ្វើឡើង៖

- ដោយអនុលោមទៅតាមច្បាប់ និងបទដ្ឋាននានា។
- ព័ត៌មានពាក់ព័ន្ធនឹងការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តត្រូវផ្សព្វផ្សាយជាចំហ តាមរយៈប្រព័ន្ធផ្សព្វផ្សាយដែលសមស្រប និងអាចស្វែងរកបានជាពិសេសចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់ពីការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តទាំងនោះ។
- ព័ត៌មានទាំងនោះត្រូវតែមានលក្ខណៈគ្រប់គ្រាន់ និងងាយយល់។

**១.៥.៤ ការព្រមព្រៀងឯកភាពគ្នា**

ការព្រមព្រៀងឯកភាពគ្នាក្នុងន័យអភិបាលកិច្ចល្អ គឺជាការពិចារណាទូលំទូលាយ និងវែងឆ្ងាយលើផលប្រយោជន៍ និងតម្រូវការរបស់អ្នកពាក់ព័ន្ធផ្សេងៗគ្នានៅក្នុងសង្គម ហើយឈានទៅរកការសម្រេចចិត្តដោយមានការព្រមព្រៀងឯកភាពគ្នាលើជម្រើស និងវិធីសាស្ត្រណាមួយ ដែលបម្រើផលប្រយោជន៍សាធារណៈ។

**១.៥.៥ សមធម៌**

សមធម៌ក្នុងន័យអភិបាលកិច្ចល្អមានន័យថាក្រុម ឬជនគ្រប់រូបទាំងអស់ជាពិសេស ក្រុម ភាគតិច និងក្រុមដែលងាយរងគ្រោះ មានឱកាសគ្រប់គ្រាន់នៅក្នុងការចូលរួមបញ្ចេញយោបល់លើកឡើងនូវតម្រូវការពិត អនុវត្តសកម្មភាព និងទទួលផលប្រយោជន៍សមស្រប ដើម្បីកែលម្អនិងថែរក្សាសុខុមាលភាពរបស់ពួកគេ។ សុខុមាលភាពរបស់សមាជិក ឬក្រុមនីមួយៗ គឺជាសុខុមាលភាពរបស់សង្គមទាំងមូល។

**១.៥.៦ ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ**

ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងន័យអភិបាលកិច្ចល្អ មានន័យថាជាដំណើរការ និងរចនាសម្ពន្ធគ្រប់គ្រងក្នុង ការប្រើប្រាស់ធនធានឲ្យអស់លទ្ធភាព និងសន្សំសំចៃខ្ពស់ដើម្បីបង្កើតលទ្ធផលដែលមានគុណភាពខ្ពស់ បរិមាណច្រើនអាចបម្រើផលប្រយោជន៍ជាអតិបរមា និងបានឆ្លើយតបទៅតម្រូវការពិតរបស់សង្គម។ គោល

គំនិតនៃភាពស័ក្តិសិទ្ធិ នៅក្នុងបរិបទអភិបាលកិច្ចល្អក៏បានបញ្ចូលផងដែរ ចំពោះការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយនិរន្តន៍ភាព និងការការពារបរិស្ថាន។

### ១.៥.៧ គណនេយ្យភាព

គណនេយ្យភាពក្នុងន័យអភិបាលកិច្ចល្អ មានន័យថាជាការអនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរការ និងអនុវត្តសេចក្តីសម្រេចចិត្ត ហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដោយរាយការណ៍ ព្រមទាំងបញ្ជាក់ពីមូលហេតុនូវអ្វីដែលខ្លួនបានសម្រេច និងអនុវត្ត។

គណនេយ្យភាពមិនត្រឹមតែជាការទទួលចំពោះមុខអ្នកណាម្នាក់ ដែលបានស្នើសុំឲ្យធ្វើអ្វីមួយនោះទេប៉ុន្តែជាការទទួលខុសត្រូវនូវសកម្មភាពដែលបានអនុវត្តចំពោះមុខអ្នកពាក់ព័ន្ធទាំងអស់ផងដែរ។ គណនេយ្យភាពរួមមានគណនេយ្យភាពចំពោះមុខថ្នាក់ដឹកនាំនិងគណនេយ្យភាពចំពោះមុខសាធារណជន។

### ១.៥.៨ ការឆ្លើយតប

ការឆ្លើយតបក្នុងន័យអភិបាលកិច្ចល្អមានន័យថា ជាការព្យាយាម ខិតខំប្រឹងប្រែងរបស់អង្គភាព ស្ថាប័ន ដើម្បីបម្រើដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ដោយស្មើភាពគ្នា និងមិនរើសអើងនៅក្នុងក្របខណ្ឌពេលវេលាមួយដ៏សមហេតុផល។

ការឆ្លើយតបអាចជា៖

- ការបំពេញសេវាកម្មជូនប្រជាពលរដ្ឋតាមការស្នើសុំ។
- ដំណោះស្រាយដែលស្តែងឡើងជាសកម្មភាព ដើម្បីដោះស្រាយបញ្ហា ឬការលំបាកនានា។
- ការឆ្លើយបំភ្លឺអំពីមូលហេតុ ដែលមិនអាចឈានដល់ការធ្វើសកម្មភាព ដើម្បីដោះស្រាយបញ្ហា ឬការលំបាកទាំងនោះបាន។
- សំណើរសុំអន្តរាគមន៍ពីស្ថាប័ន អង្គភាពមានសមត្ថកិច្ច ដើម្បីជួយដោះស្រាយបញ្ហា ឬការលំបាកទាំងនោះ ព្រមទាំងជំរាបអំពីសំណើសុំអន្តរាគមន៍នេះដល់ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងបញ្ហា ឬការលំបាកទាំងនោះ។

### ១.៥.៩ ចក្ខុវិស័យជាយុទ្ធសាស្ត្រ

អ្នកដឹកនាំទាំងអស់ និងស្ថាប័នសាធារណៈនានាត្រូវមានទស្សនៈទូលំទូលាយ និងសម្រាប់រយៈពេលវែងអំពីអភិបាលកិច្ចល្អ និងការអភិវឌ្ឍធនធានមនុស្សដោយយកចិត្តទុកដាក់អំពីតម្រូវការ ចាំបាច់នានាដែលត្រូវអភិវឌ្ឍន៍លើការងារនេះ។ ជាងនេះទៀត អ្នកដឹកនាំទាំងអស់ត្រូវមានការយល់ដឹងឲ្យបានច្បាស់អំពីទិដ្ឋភាពនានាផ្នែកប្រវត្តិសាស្ត្រ វប្បធម៌ និងសង្គម ដែលពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ។[12]

[12] ក្រសួងមហាផ្ទៃ (២០១០), *អភិបាលកិច្ចល្អ* (បោះពុម្ពលើកទី២)

## ១.៦ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាពាក្យដែលរដ្ឋាភិបាលប្រើដើម្បីធ្វើការពិពណ៌នាពីគោលដៅ នៃកំណែទម្រង់អភិបាលកិច្ចល្អ នៅថ្នាក់ក្រោមជាតិ។ ពាក្យ "ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ" ត្រូវបានគេដកស្រង់ចេញមកពីរដ្ឋធម្មនុញ្ញ។ តម្លៃស្នូលដ៏សំខាន់ទាំងពីរ ដែលបានឆ្លុះបញ្ចាំងនៅក្នុងរដ្ឋធម្មនុញ្ញគឺលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍ។ ពាក្យ " ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ" មានប្រភពមកពីការរួមបញ្ចូលគ្នានូវតម្លៃស្នូលទាំងពីរខាងលើ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងបង្កើតឱ្យមាននូវបរិយាកាសនៃលទ្ធិប្រជាធិបតេយ្យ ដែលមានការចូលរួមនៅមូលដ្ឋាន។ បរិយាកាសនេះមានន័យថា ជាការប្រគល់អំណាចឱ្យដល់ប្រជាជនខ្មែរ ដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចលើបញ្ហាដែលមានការប៉ះពាល់ដល់ការរស់នៅរបស់ពួកគេ។ បរិយាកាសនេះក៏មានន័យដែរថា ជាការផ្តល់អំណាចបន្ថែមទៀតដល់ប្រជាជនកម្ពុជា ដើម្បីធានាថាអភិបាលកិច្ចមូលដ្ឋានមានគណនេយ្យភាព និងមានការឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ពួកគេ។

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ត្រូវបានគេប្រមើលមើលទៅលើក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិទាំងអស់ដែលប្រកបទៅដោយសមត្ថភាព និងត្រូវបានធ្វើការបោះឆ្នោតជ្រើសរើសឡើងដោយផ្ទាល់ ឬដោយប្រយោល។ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រមើលមើលថា ក្រុមប្រឹក្សាទាំងនោះនឹងមានមុខងារផង និងធនធានផង (ហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិ) ចាំបាច់ឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍របស់មូលដ្ឋាន។

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានសមាសភាពចំនួន៨គឺ (១) ភាពជាតំណាងសាធារណៈ (២) ស្វ័យភាពរបស់មូលដ្ឋាន (៣) ការពិគ្រោះយោបល់ និងការចូលរួម (៤) ការឆ្លើយតប និងគណនេយ្យភាព (៥) ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន (៦) ការលើកស្ទួយសមធម៌ (៧) តម្លាភាព និងសុចរិតភាព និង (៨) វិធានការប្រឆាំងអំពើពុករលួយ និងរំលោភអំណាច។[13]

## ១.៧ រដ្ឋបាលឯកភាព

រដ្ឋបាលឯកភាព គឺជាការរៀបចំឲ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធានរាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ របស់ខ្លួន ហើយក្រុមប្រឹក្សានីមួយៗនោះមានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀតដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។[14]

[13] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលដែនដី ឆ្នាំ២០១២ សាស្ត្រាចារ្យ ហៀង សាង និងអនុបណ្ឌិត ប៉េង ឆុង

[14] *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨)*

## ១.៨ គណនេយ្យភាព

គណនេយ្យភាព គឺជាកាតព្វកិច្ចរបស់អ្នកដែលទទួលបាននូវការទទួលខុសត្រូវ និងសិទ្ធិអំណាចដើម្បីឆ្លើយបំភ្លឺ និងទទួលខុសត្រូវចំពោះទង្វើនានារបស់ខ្លួន រួមទាំងផលវិបាកដែលកើតឡើងពីទង្វើទាំងនេះ។[15]

គណនេយ្យភាពសង្គម គឺជាដំណើរការនៃការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើររវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយវាក៏ជាមធ្យោបាយមួយដែលបន្សីគ្នារវាងគោលការណ៍ទាំងឡាយនៃអភិបាលកិច្ចដែលក្នុងនោះរាល់ការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសកម្មភាពជាសាធារណៈនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានប្រកាន់យកតាមកិច្ចដំណើរការ។

## ១.៩ ក្រុមប្រឹក្សា

ក្រុមប្រឹក្សាគឺជានីតិបុគ្គលដែលបង្កើតឡើងដោយច្បាប់ ដើម្បីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាត្រូវបានជ្រើសរើសឡើងដោយការបោះឆ្នោតអសកល ដោយតម្រូវឱ្យសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាអ្នកចូលរួមបោះឆ្នោតជ្រើសរើស និងមានអាណត្តិប្រាំ(៥)ឆ្នាំ។ ក្រុមប្រឹក្សាជាអ្នកតំណាងឱ្យប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាទទួលខុសត្រូវក្នុងការគ្រប់គ្រងចាត់ចែងរាល់កិច្ចការនានា នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិ តាមរយៈការធ្វើដីការបស់ក្រុមប្រឹក្សា និងសិទ្ធិអំណាចប្រតិបត្តិតាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។

## ១.១០ គណៈអភិបាល

គណៈអភិបាលគឺជានីតិបុគ្គលដែលបង្កើតឡើងដើម្បីដឹកនាំ គ្រប់គ្រងរដ្ឋអំណាចអាជ្ញាធរ មូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ គណៈអភិបាលត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ។ គណៈអភិបាលមានតួនាទី និងភារកិច្ចក្នុងការធ្វើការស្រាវជ្រាវដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាអំពីកិច្ចការនានា ដែលពាក់ព័ន្ធនឹងសិទ្ធិអំណាចខាងបញ្ញត្តិ និងសិទ្ធិអំណាចខាងប្រតិបត្តិ ដើម្បីក្រុមប្រឹក្សាធ្វើការពិភាក្សាអនុម័ត ក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញ។ ក្រៅពីបំពេញតួនាទីក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន អភិបាលគឺជាតំណាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលក្នុងការណែនាំសម្របសម្រួលតម្រង់ទិសដល់មន្ទីរអង្គភាពខ្សែបណ្តោយរបស់ក្រសួងស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាលដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ជាមួយគ្នានេះ អភិបាលត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការងារសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់សិទ្ធិមនុស្សក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ១.១១ នាយករដ្ឋបាល

នាយករដ្ឋបាលជាអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ នាយករដ្ឋបាលត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នាយករដ្ឋបាលមានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។

---

[15] *កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩)*

នាយករដ្ឋបាលជាអ្នកអនុវត្តដីការបស់ក្រុមប្រឹក្សាចូលរួម និងមានយោបល់រាល់កិច្ចការប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតទេ។[16]

[16] *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨)*

# ជំពូកទី២

# ស្ថានភាពទូទៅ

## ២.១ សម័យសង្គមរាស្ត្រនិយម

**(ឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៧០)**

សម័យសង្គមរាស្ត្រនិយម មានការបែងចែក និងគ្រប់គ្រងរដ្ឋត្រូវបែងចែកដូចខាងក្រោម៖

### ២.១.១ ការបែងចែកដែនដី

ព្រះរាជាណាចក្រកម្ពុជាទាំងមូល ត្រូវបែងចែកជា៖

- ភូមិភាគមានចំនួន៨ភូមិភាគ

- ភូមិភាគនីមួយៗ មានខេត្តមួយឬច្រើន អាស្រ័យតាមស្ថានភាពជាក់ស្តែង។

ទាំងនេះ មិនមែនជាមណ្ឌលរដ្ឋបាលទេ គឺគ្រាន់តែជាមណ្ឌលបោះឆ្នោតប៉ុណ្ណោះ។ មណ្ឌលបោះឆ្នោតត្រូវជ្រើសរើសតំណាងម្នាក់ ដើម្បីធ្វើជាសមាជិកនៃក្រុមប្រឹក្សាព្រះរាជាណាចក្រ។

- ខេត្តត្រូវបែងចែកជាស្រុក

- ស្រុកត្រូវបានបែងចែកជាឃុំ។

### ២.១.២ ការគ្រប់គ្រងរដ្ឋបាលដែនដី

នៅក្នុងប្រទេសកម្ពុជាសម័យនោះ យើងយកគំរូចាត់តាំងដែនដីតាមបែបប្រទេសបារាំង។ នៅថ្នាក់ខេត្ត និងឃុំ និងវិសហមជ្ឈការពីថ្នាក់កណ្តាលទៅថ្នាក់តំបន់។

នៅតាមបណ្តាខេត្ត និងរាជធានី មានការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ ពោលគឺមាន៖

### ក. សភាប្រជារាស្ត្រប្រចាំខេត្ត និងប្រចាំរាជធានី

*លក្ខខណ្ឌនៃសមាជិក*

សមាជិកនៃសភានេះ ត្រូវជ្រើសតាំងតាមវិធីបោះឆ្នោតជាសាកលនិងចំពោះ។ អ្នកដែលមានសិទ្ធិបោះឆ្នោតគឺពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិចម្ភៃប្រាំឆ្នាំ មានទីលំនៅនៅក្នុងស្រុក ឬនៅក្នុងសង្កាត់នោះ។ សភាខាងលើនេះ ត្រូវប្រជុំនៅទីប្រជុំខេត្ត ឬនៅរាជធានីក្នុងមន្ទីរមួយជាក់លាក់។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនឲ្យគេបោះឆ្នោតជ្រើសរើសតាំង ជាសមាជិកសភាប្រជារាស្ត្របាននោះ គឺពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិចម្ភៃប្រាំឆ្នាំបរិបូរណ៍ឡើងទៅ។

*អាណត្តិនៃសមាជិក*

សមាជិកសភាប្រជារាស្ត្រ ត្រូវបានជ្រើសតាំងសម្រាប់អាណត្តិពីរឆ្នាំ។ អាណត្តិនេះនឹងត្រូវបដិសេធចោលមុនបាន។

*សិទ្ធិ និងភារកិច្ច*

សមាជិកសភាប្រជារាស្ត្រខេត្ត និងរាជធានី ត្រូវបំពេញលក្ខណសម្បត្តិដូចតំណាងរដ្ឋសភាដែរ ហើយត្រូវមានសិទ្ធិ និងអភ័យឯកសិទ្ធិដូចរដ្ឋសភាដែរ ប៉ុន្តែត្រូវទទួលប្រាក់បំណាច់តិចជាងប្រាក់បំណាច់របស់សមាជិករដ្ឋសភា។ ប្រាក់បំណាច់នេះត្រូវកំណត់តាមច្បាប់ដោយប្រៀបស្មើទៅនឹងប្រាក់បៀវត្សអ្នករាជការថ្នាក់ណាមួយនៃក្របខណ្ឌបន្ទាប់។

សភាប្រជារាស្ត្រខេត្ត និងរាជធានី ត្រូវមានការបញ្ចេញមតិជូនយោបល់ចំពោះនូវការអនុម័តនៅថវិកាជាតិ សេចក្ដីព្រាងនានារបស់រដ្ឋាភិបាល។ ឯសន្ធិសញ្ញាដែលត្រូវជាមួយបរទេសក៏ត្រូវបានដាក់ឲ្យសភានេះ ជូនយោបល់ផងដែរ។ សភាប្រជារាស្ត្រខេត្ត និងរាជធានីត្រូវអនុម័តចំពោះថវិកាខេត្ត និងរាជធានី ព្រមទាំងថវិកាឃុំដែលនៅក្នុងដែនចំណុះរបស់ខ្លួន ហើយអនុម័តចំពោះបញ្ជីស្រង់ប្រាក់ចំណូលចំណាយផ្ដាច់ឆ្នាំនៃសមូហភាពទាំងនេះ។ សភាទាំងនេះមានសិទ្ធិសម្រេចង្កើត ឬលុបពន្ធអាករសម្រាប់ខេត្ត ឬសម្រាប់រាជធានីក្នុងដែនចំណុះរបស់ខ្លួនក្នុងក្របខណ្ឌនៃច្បាប់ទាំងឡាយដែលរដ្ឋសភាបានអនុម័តហើយ។

សភាប្រជារាស្ត្រខេត្ត និងរាជធានីមានសិទ្ធិធ្វើញត្តិជូនដល់រដ្ឋសភា ឬរាជរដ្ឋាភិបាល អំពីការចាត់ចែងនៃរាជការសាធារណៈក្នុងផែនការជាតិ។ សភាប្រជារាស្ត្រខេត្ត និងរាជធានីត្រូវតាមពិនិត្យមើលរាជការចាត់ចែងការសាធារណៈក្នុងខេត្ត ឬរាជធានី។

**ខ. <u>អំពីរាជធានី</u>**

ក្រុងភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវគ្រប់គ្រងដោយរាជប្រតិភូក្រុង។ សមាជិកប្រជារាស្ត្ររាជធានី មានអាណត្តិ២ឆ្នាំដោយសារការបោះឆ្នោតជាសាកល និងចំពោះ។ ក្រុងភ្នំពេញ ត្រូវបែងចែកជា៧សង្កាត់ ដែលគ្រប់គ្រងដោយប្រធានសង្កាត់ឬចៅសង្កាត់ម្នាក់ តែងតាំងដោយប្រកាសរបស់ប្រតិភូក្រុងភ្នំពេញ។

**គ. <u>អំពីខេត្ត</u>**

ខេត្ត បង្កើតជាសមូហភាពដែនដី ពីព្រោះមានសភាប្រជារាស្ត្រប្រចាំខេត្តក្នុងការកំណត់ ឬញត្តិនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយត្រូវគ្រប់គ្រងដោយទេសាភិបាល ឬចៅហ្វាយខេត្ត និងមានប្រឈួយខេត្តជាជំនួយការ។ សមាជិកសភាប្រជារាស្ត្រខេត្តមានអាណត្តិ២ឆ្នាំ ដោយសារការបោះឆ្នោតជាសាកល និងចំពោះ។ ខេត្តត្រូវចែកចេញជាស្រុក ដែលគ្រប់គ្រងដោយប្រធានស្រុកឬចៅហ្វាយស្រុក និងបាឡាត់ស្រុកជាជំនួយការ។

**ឃ. <u>អំពីឃុំ</u>**

ឃុំមានលក្ខណៈជានីតិបុគ្គលក្នុងន័យនេះ ឃុំមានសិទ្ធិកម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ឃុំទាំងអស់ និងសិទ្ធិស្វ័យសម្រេចនៅក្នុងដែនដីរបស់ខ្លួនតាមអំណាចច្បាប់ជាធរមាន។ ចំណែកការគ្រប់គ្រងវិញ ឃុំបានរៀបចំ

អង្គការសមូហភាពមួយសម្រាប់សម្រេចកិច្ចការនានាក្នុងដែនដីឃុំដែលគេហៅថា ក្រុមប្រឹក្សាឃុំ។ សមាជិកក្រុមប្រឹក្សានេះមានអាណត្តិ៤ឆ្នាំ ជ្រើសតាំងដោយការបោះឆ្នោតជាសាកល និងចំពោះ។ ក្រុមប្រឹក្សានេះមានភារកិច្ចកំណត់ទិសដៅ និងត្រួតពិនិត្យសកម្មភាពរបស់ឃុំ។

ចំណែកសកម្មភាពរបស់ឃុំដឹកនាំដោយមេឃុំ ដែលមានតួនាទីជាតំណាងឲ្យរដ្ឋផងនិងតំណាងឲ្យសមូហភាពផង។

## ២.២ សម័យសាធារណរដ្ឋខ្មែរ

**(ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥)**

ចាប់តាំងពីរដ្ឋបាលថ្មីបង្កើតឡើងរបបគ្រប់គ្រងរដ្ឋ ត្រូវបានផ្លាស់ប្តូរពីរបបរាជានិយម មករបបថ្មីគឺ របបសាធារណរដ្ឋខ្មែរ។ របបសាធារណរដ្ឋខ្មែរនេះត្រូវបានបង្កើតឡើងដោយដោយស្របច្បាប់ ព្រោះមានការបោះឆ្នោតជាសម្ងាត់នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៧០ យោងតាមច្បាប់នៃការបោះឆ្នោត ដែលជាច្បាប់មួយអាស្រ័យរដ្ឋធម្មនុញ្ញដោយបញ្ញត្តិថាការប្រកាសនេះនឹងប្រព្រឹត្តទៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧០។

ក្នុងសម័យសាធារណរដ្ឋខ្មែរ មានការជ្រើសរើសថ្នាក់ដឹកនាំប្រទេសដោយការបោះឆ្នោត ព្រមទាំងមានការបង្កើតរដ្ឋធម្មនុញថ្មីរបស់សាធារណរដ្ឋនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២ (ក្នុងរដ្ឋធម្មនុញ្ញមានគ្រោងបោះឆ្នោតនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៧២)។

ក្រោយពីលទ្ធផលនៃការបោះឆ្នោត ការគ្រប់គ្រងរដ្ឋត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកឧត្តមសេនីយ៍ លន់ នល់ ជាប្រធានាធិបតីដូចជាប្រធានាធិបតីនៃប្រទេសអាមេរិកដែរ។

## ២.៣ សម័យកម្ពុជាប្រជាធិបតេយ្យ

**(ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៧៩)**

បន្ទាប់ពីមានភាពរង្គោះរង្គើផ្នែកនយោបាយ សង្គមកិច្ច និងសេដ្ឋកិច្ចក៏ដូចជារបបគ្រប់គ្រងរដ្ឋនាសម័យសាធារណរដ្ឋខ្មែរអស់រយៈពេល៥ឆ្នាំ ប្រទេសកម្ពុជាបានធ្លាក់ក្នុងសង្គ្រាមស៊ីវិលយ៉ាងក្តៅគគុកនៅដើមឆ្នាំ១៩៧៥ ដោយសារស្ថានភាពនយោបាយពុំមានស្ថិរភាព និងអំពើពុករលួយក្នុងជួររដ្ឋាភិបាល ធ្វើឱ្យមានអត្រាអតិផរណា និងអត្រានិកម្មភាពកាន់តែខ្ពស់ វិសមភាពសង្គម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែលំបាកខ្លាំងឡើងៗ បានធ្វើឲ្យប្រជាពលរដ្ឋមួយភាគធំនៅតាមតំបន់ជនបទ ក្រោមការដឹកនាំរបស់គណៈបក្សកុម្មុយនីស្តមួយ ត្រូវបានបង្កើតឡើងដើម្បីរៀបចំប្រទេសជាតិ និងខឿនសេដ្ឋកិច្ចជាតិឡើងវិញ។ ក្រោយពីផ្តួលរំលំរបបសាធារណរដ្ឋខ្មែរ ប្រទេសកម្ពុជាត្រូវបានរៀបចំដោយគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលជាស្ថាប័នរដ្ឋបាលកណ្តាល ឬជាក្បាលម៉ាស៊ីនដឹកនាំរដ្ឋ។

បក្សកុម្មុនីស្តកម្ពុជាបានបែងចែកជាតំបន់ជាភូមិភាគធំៗគឺះ

១. ភូមិភាគនិរតីទិសះ ខេត្តកំពត កោះកុង ក្រុងព្រះសីហនុ កំពង់សីលា តាកែវ កំពង់ឆ្នាំង កំពង់ស្ពឺ ឧត្តុង្គ និងខេត្តកណ្តាល។

២. ភូមិភាគបូព៌ាទិសៈ ខេត្តក្រចេះ ស្វាយរៀង ព្រៃវែង កំពង់ចាម។
៣. ភូមិភាគពាយ័ព្យទិសៈ កំពង់ធំ សៀមរាប ឧត្តរមានជ័យ បន្ទាយឆ្មារ។
៤. ភូមិភាគពោធិ៍សាត់-បាត់ដំបង-ប៉ៃលិន។
៥. ភូមិភាគពិសេសៈ នៅតាមព្រំប្រទល់កំពង់ស្ពឺ និងកំពង់ឆ្នាំង ក្នុងសង្កាត់ពាមប្រាំបីមុម ប៉ែកខាងត្បូងក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ស្ពឺ (ស្រុកបរសេត) និងខេត្តកណ្តាល (ស្រុក កណ្តាលស្ទឹង ស្រុកស្អាង កោះធំ)។
៦. ខេត្តព្រះវិហារ ស្ទឹងត្រែង មណ្ឌលគិរី និងរតនគិរី ត្រូវបានគណៈកម្មាធិការមជ្ឈិម នៃបក្សកុម្មុយនីស្តខ្មែរបានកាន់កាប់ដោយផ្ទាល់។

ភូមិភាគនីមួយៗ ចែកជាតំបន់ ជាស្រុក ជាឃុំ ភូមិ។ លេខាធិការ ឬប្រធានភូមិភាគនីមួយៗ មានឥទ្ធិពលខ្លាំងណាស់លើភូមិភាគរបស់ខ្លួន។ ពួកគេទទួលខុសត្រូវទាំងស្រុងលើអំណាច នយោបាយ រដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច និងយោធា។ ប្រធានភូមិភាគ ឬលេខាភូមិភាគ ជាសមាជិកក្នុងគណៈមជ្ឈិមបក្ស។

## ២.៤. សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា (ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩-ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣)

ស្ថាប័នរដ្ឋបាលនៃសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា សុទ្ធតែបានបង្កើតឡើងដោយរដ្ឋដើម្បីបម្រើផលប្រយោជន៍រួម និងការរស់នៅប្រចាំថ្ងៃ ព្រមទាំងស្ថិតនៅក្រោមការដឹកនាំរបស់អង្គការនីតិប្រតិបត្តិ។

ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្រុមប្រឹក្សារដ្ឋមន្ត្រីជារដ្ឋាភិបាល ជាអង្គការគ្រប់គ្រងសង្គមដោយផ្ទាល់ និងដឹកនាំការពង្រីកសេដ្ឋកិច្ចជាតិដោយផ្ទាល់។ ក្រុមប្រឹក្សារដ្ឋមន្ត្រី ក៏ជាអង្គការប្រតិបត្តិរបស់រដ្ឋសភាព្រមទាំងជាអង្គការរដ្ឋបាលខ្ពស់បំផុត ដែលទទឹមនឹងនេះ ជាអង្គការគ្រប់គ្រងសេដ្ឋកិច្ច និងគ្រប់គ្រងសង្គមខ្ពស់បំផុតរបស់ប្រទេសជាតិទាំងមូល។

យោងតាមមាត្រា ៣៣ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាជំពូកទី១ និងទី២ (ក្រឹត្យលេខ ០៣ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២)[17] ក្រុមប្រឹក្សារដ្ឋមន្ត្រីមានឧទ្ទកាល័យមួយជាក្បាលម៉ាស៊ីនជំនួសក្រុមប្រឹក្សារដ្ឋមន្ត្រីដឹកនាំដោយរដ្ឋមន្ត្រីមួយរូប។ ការបង្កើតទីស្តីការក្រសួងមានការកំណត់រួចជាស្រេចនូវភារកិច្ចរបស់ក្រសួងជំនួសការកំណត់វិស័យសមត្ថកិច្ច។ ការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការក្រសួងត្រូវកំណត់ដោយអនុក្រឹត្យ ដែលជាសមត្ថកិច្ចរបស់រដ្ឋាភិបាល។ ជារួមក្រសួងនីមួយៗត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូបមានអនុរដ្ឋមន្ត្រី ឬឧបការីមួយចំនួនជាជំនួយការ។ ចំណែកឯរចនាសម្ពន្ធរបស់ក្រសួងមានជារួមៈ

[17] សួង លាង ហៃ (២០១០). *ការវិវត្តនៃរដ្ឋបាលកម្ពុជា* (១៩៩៣-២០០៨) [និក្ខេបបទបណ្ឌិតវិទ្យាសាស្ត្រនយោបាយ]. មហាវិទ្យាល័យមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ.

- អង្គភាពចំណុះផ្ទាល់ក្រសួងៈ
  - មន្ទីរ
  - នាយកដ្ឋាន
  - គ្រឹះស្ថានសាធារណៈផ្សេងៗ។
- អង្គភាពចំណុះគណៈកម្មាធិការប្រជាជនបដិវត្តៈ
  - មន្ទីរខេត្ត ក្រុង
  - ការិយាល័យស្រុក ឃុំ.....។

ដូចនេះយើងឃើញថា មុនឆ្នាំ១៩៨៩ ដែនដីត្រូវបែងចែកជា ខេត្ត ក្រុង ចំណុះឱ្យរដ្ឋអំណាចមជ្ឈិម ដែលក្នុងនោះខេត្តចែកចេញជាស្រុក ក្រុង ឃុំ ។ល។ ហើយរដ្ឋបាលដែនដីត្រូវគ្រប់គ្រងដោយគណៈកម្មាធិការប្រជាជនបដិវត្តមូលដ្ឋានមានថ្នាក់ខេត្ត និងស្រុកជាដើម[18]។

ប្រកាសនៅថ្ងៃទី៣០ ខែមេសាឆ្នាំ ១៩៨៩ ប្រទេសកម្ពុជានៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាបានផ្លាស់ប្តូរឈ្មោះប្រទេសរបស់ខ្លួនជារដ្ឋកម្ពុជា ក៏ប៉ុន្តែបន្ទាត់នយោបាយធំៗ ក៏ដូចជាការគ្រប់គ្រងរដ្ឋបាលដែនដីនៅតែមានលក្ខណៈប្រហាក់ប្រហែលទៅនឹងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយគ្រាន់តែមានការផ្លាស់ប្តូរបន្តិចបន្តួច។ ជាក់ស្តែង មាត្រា ៧១ នៃរដ្ឋធម្មនុញ្ញរបស់រដ្ឋកម្ពុជាបានចែកថា ដែនដីត្រូវចែកជាខេត្ត និងក្រុង។

- ខេត្ត ចែកជាទីរួមខេត្ត និងស្រុក។ ទីរួមខេត្ត ចែកជាសង្កាត់ ហើយស្រុក ចែកជាឃុំ។
- ក្រុង ចែកចេញជាខណ្ឌ និងសង្កាត់ព្រម ទាំងមានខណ្ឌជាយក្រុង និងតំបន់ជាយក្រុងថែមទៀតផង។

នៅសម័យរដ្ឋកម្ពុជារដ្ឋបាលដែនដីត្រូវគ្រប់គ្រងដោយគណៈកម្មាធិការប្រជាជនទាំងមូលមានថ្នាក់ខេត្ត និងស្រុកជាដើម។

បើទោះបីជាយ៉ាងដូច្នោះក្តី សមាជិកគណៈកម្មាធិការប្រជាជនបដិវត្ត នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និងគណៈកម្មាធិការប្រជាជន នៃរដ្ឋកម្ពុជា ត្រូវជ្រើសរើសតាមគោលការណ៍បោះឆ្នោតជាសកលដោយស្មើភាព ដោយចំពោះ និងដោយសម្ងាត់ ដែលស្ថិតនៅតាមតំបន់នីមួយៗឯកជនទាំងនោះជាតំណាងគណៈកម្មាធិការប្រជាជនតំណាងរណសិរ្សនិងតំណាងអង្គការមហាជននានា។ ប្រធាននៃសមាជិកនៃគណៈកម្មាធិការទាំងពីរមានអាណត្តិ៥ឆ្នាំ ចំពោះគណៈកម្មាធិការថ្នាក់ខ្ពស់ និងអាណត្តិ៣ឆ្នាំ ចំពោះគណៈកម្មាធិការថ្នាក់ទាប។

## ២.៥ សម័យព្រះរាជាណាចក្រកម្ពុជា

**(ឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៨)**

ស្ថាប័នរដ្ឋបាលកណ្តាល ជាក្បាលម៉ាស៊ីនដឹកនាំរាល់កិច្ចការរដ្ឋបាលលើគ្រប់វិស័យទាំងអស់របស់រដ្ឋ

[18] ពៅ សាវឿន. (២០១០). *ប្រវត្តិស្ថាប័នខ្មែរ* (បោះពុម្ពលើកទី១). ភ្នំពេញ.

ហើយស្ថាប័ននេះកាន់កាប់ដោយទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាកន្លែងនាយករដ្ឋមន្ត្រី និងសមាជិកដទៃទៀតរបស់គណៈរដ្ឋមន្ត្រីបំពេញការងារព្រមទាំងជាទីស្តីការក្រសួងជំនាញនានា និងរដ្ឋលេខាធិការដ្ឋានដែលចំណុះឱ្យនាយករដ្ឋមន្ត្រីផ្ទាល់។ ស្ថាប័នរដ្ឋបាលកណ្តាលមានពីរលំដាប់ គឺលំដាប់ថ្នាក់រាជរដ្ឋាភិបាល និងលំដាប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។ ចំណែកស្ថាប័នរដ្ឋបាលដែនដី គឺជាស្ថាប័ននៅឯរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សម្រាប់អនុវត្តសេចក្តីសម្រេចរបស់ស្ថាប័នរដ្ឋបាលកណ្តាល ដើម្បីគ្រប់គ្រងដែនដីរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ជូនប្រជារាស្ត្រក្នុងនាមស្ថាប័នរដ្ឋបាលកណ្តាល និងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ស្ថាប័នរដ្ឋបាលកណ្តាល។

រដ្ឋបាលខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាប័នចំណុះក្រសួងមហាផ្ទៃផ្ទាល់ និងជាតំណាងរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងដែនដី នៃខេត្ត-ក្រុង មានវិសាលភាព និងសមត្ថភាពគ្រប់គ្រងលើវិស័យរដ្ឋបាល និងនយោបាយ ដើម្បីធានារក្សាសន្តិសុខសាធារណៈ ការពារសិទ្ធិ សេរីភាព លើកតម្កើនកម្រិតជីវភាពរស់នៅ និងឈានទៅដល់ការអភិវឌ្ឍលើគ្រប់វិស័យ។ រដ្ឋបាលដែនដីនៃព្រះរាជាណាចក្រកម្ពុជាមុនឆ្នាំ២០០៨ បានបែងចែកជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ។ រាជធានី ខេត្ត ក្រុង គឺជាថ្នាក់រដ្ឋបាលខ្ពស់បំផុត នៃរដ្ឋបាលដែនដី។

### ២.៥.១ **<u>អំពីរាជធានី ខេត្ត-ក្រុង</u>**

រាជធានី និងខេត្ត-ក្រុង នីមួយៗដឹកនាំដោយ អភិបាលរាជធានី ខេត្ត-ក្រុង មួយរូប និងអភិបាលរង ៣រូប។




តារាងទី ១ ៖ រចនាសម្ពន្ធគ្រប់គ្រងរបាលរាជធានី ខេត្ត-ក្រុង

រដ្ឋបាល រាជធានី ខេត្ត-ក្រុង មានភារកិច្ច និងសិទ្ធិដូចតទៅ៖ ផ្សព្វផ្សាយ អនុវត្ត តាមដាន ត្រួតពិនិត្យការអនុវត្តកម្មវិធីនយោបាយ នៃរាជរដ្ឋាភិបាលព្រះរាជក្រម ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស បទបញ្ជា និងលិខិតបទដ្ឋាននានា។

- ផ្តល់ព័ត៌មាន និងធ្វើរបាយការណ៍ជូនក្រសួងមហាផ្ទៃ អំពីមតិសាធារណៈ ហេតុការណ៍ និងសភាពការណ៍ទូទៅ នៅក្នុងរាជធានី ខេត្ត ក្រុង។
- មានអំណាចតាមឋានានុក្រមលើចៅក្រសួងនានានៅក្នុងរាជធានី ខេត្ត ក្រុង ដូចជាការដាក់ពិន្ទុមូលវិចារណ៍ ស្នើតំឡើងឋានន្តរស័ក្តិ ជូនមតិលើកសំណើតែងតាំង ផ្លាស់ប្តូរ អនុញ្ញាតច្បាប់ឈប់សម្រាក។
- សម្រួលសម្រួល ជំរុញ និងត្រួតពិនិត្យលើសកម្មភាពរបស់ចៅក្រសួង ស្ថាប័ន និងអង្គការនានានៅក្នុងរាជធានី ខេត្ត ក្រុង។
- មានអំណាចឋានានុក្រម លើរដ្ឋបាល ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងបុគ្គលិក ដែលទទួលប្រាក់បៀវត្សនៅក្នុងតណទាននៃថវិកាជាតិ និងថវិការាជធានី ខេត្ត ក្រុង បើមាន។
- ចាត់វិធានការ ដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ភាពស្ងប់ស្ងាត់ សន្តិសុខ និងនាំមកនូវសុខមាលភាពជូនប្រជារាស្ត្រ។
- ត្រួតពិនិត្យ និងបញ្ជាមន្ត្រីស្រុក-ខណ្ឌ ឃុំ-សង្កាត់ អោយអនុវត្តរាល់ដីការបស់តុលាការ។
- គ្រប់គ្រងពន្ធនាគារខេត្ត-ក្រុង។
- ជំរឿន និងគ្រប់គ្រងការចុះបញ្ជីស្ថិតិប្រជាជន។
- ធ្វើបញ្ជីប្រជារាស្ត្រ ដែលមានសិទ្ធិបោះឆ្នោត។
- រៀបចំគំរោងថវិកាជាតិ និងថវិការាជធានី ខេត្ត ក្រុង។
- ជាអ្នកបញ្ជាចំណាយថវិកា រាជធានី ខេត្ត ក្រុង បើមាន។
- គ្រប់គ្រង និងប្រើប្រាស់ចលនទ្រព្យ និងអចលនទ្រព្យរបស់ រាជធានី ខេត្ត ក្រុង តាមការកំណត់របស់ច្បាប់។
- លើកកម្មវិធីសេដ្ឋកិច្ច សង្គម តាមដំណាក់កាលនីមួយៗស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនិងលក្ខណៈពិសេសរបស់រាជធានី ខេត្ត ក្រុងនីមួយៗ។
- ចេញលិខិតអនុញ្ញាតឲ្យធ្វើពាណិជ្ជកម្ម សិប្បកម្ម អាជីវកម្មផ្សេងៗ តាមការកំណត់របស់ច្បាប់។

**២.៥.២ អំពីស្រុក-ខណ្ឌ**

ស្រុក ខណ្ឌ ជាថ្នាក់រដ្ឋបាលចំណុះផ្ទាល់រដ្ឋបាលរាជធានី ខេត្ត ហើយស្រុក ខណ្ឌនីមួយៗដឹកនាំដោយអភិបាល១រូប និងអភិបាលរង ២រូប ទៅ ៤រូប។




តារាងទី ២ ៖ រដ្ឋបាលស្រុក-ខណ្ឌ

- អភិបាលស្រុក-ខណ្ឌ ទទួលខុសត្រូវចំពោះអភិបាលរាជធានី ខេត្ត ក្រុង។
- ការពារសិទ្ធិសេរីភាព រៀបចំកែទម្រង់ដីធ្លី និងការលម្អភូមិស្ថានឱ្យស្របតាមលក្ខណៈភូមិសាស្ត្រទំនៀមទម្លាប់ ប្រពៃណី និងបទដ្ឋានបច្ចេកទេស និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជារាស្ត្រដើម្បីឈានទៅអភិវឌ្ឍន៍ស្រុក-ខណ្ឌ លើគ្រប់វិស័យ។
- ផ្សព្វផ្សាយ អនុវត្ត និងតាមដាន ការអនុវត្តច្បាប់ និងបទបញ្ញាផ្សេងៗ។
- សម្របសម្រួល ជំរុញ និងត្រួតពិនិត្យសកម្មភាពរបស់អង្គភាពជំនាញ នៅក្នុងស្រុក-ខណ្ឌ។
- មានអំណាចឋានានុក្រម លើមន្ត្រីរាជការនៅក្នុងស្រុក-ខណ្ឌ។
- ទទួលចម្លងអត្រានុកូលដ្ឋាន និងថែរក្សាអត្រានុកូលដ្ឋានឆ្នាំចាស់ រៀបចំធ្វើជំរឿនការគ្រប់គ្រងចុះបញ្ជីស្ថិតិប្រជារាស្ត្រ។
- រៀបចំបញ្ជីពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោត។
- បញ្ជាអធិការ និងមន្ត្រីនគរបាលក្នុងឋានៈអាជ្ញាធរនគរបាលយុត្តិធម៌ និងនគរបាលរដ្ឋបាល។
- សម្របសម្រួល និងជំរុញការអនុវត្តរាល់ដីការរបស់តុលាការ។
- ជាអភិបាលពន្ធ ធ្វើបញ្ជីសារពើពន្ធ អាករ និងទទួលសិទ្ធិប្រមូលពន្ធអាករ បង់ចូលរតនាគារជាតិ។
- ត្រួតពិនិត្យបញ្ជីសត្វពាហនៈ។
- ត្រួតពិនិត្យបញ្ជី មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ។
- ពិនិត្យ និងចុះហត្ថលេខាលើការងារភូមិបាលស្រុក-ខណ្ឌ។

- លើកទឹកចិត្ត និងជំរុញការងារសាសនា ការអប់រំ ការថែរក្សាសុខភាព ប្រពៃណី វប្បធម៌ និងបេតិកភណ្ឌជាតិ។
- រាយការណ៍អំពីហេតុការណ៍ ព្រឹត្តិការណ៍ សភាពការណ៍ នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចនៅក្នុងស្រុក-ខណ្ឌ ជូនអភិបាលរាជធានី ខេត្ត ក្រុង។
- ចុះហត្ថលេខាលើសំណុំឯកសារផ្សេងៗ ដែលទាក់ទងទៅនឹងកិច្ចការស្រុក-ខណ្ឌ។
- បំពេញភារកិច្ចផ្សេងៗអភិបាលរាជធានី ខេត្ត ក្រុង ប្រគល់ឱ្យ។

### ២.៥.៣ អំពីឃុំ-សង្កាត់

រដ្ឋបាលកណ្តាល បានផ្ទេរកម្មសិទ្ធិអំណាច/ការទទួលខុសត្រូវលើការសម្រេចចិត្ត និងការគ្រប់គ្រងរដ្ឋបាលសាធារណៈទៅឱ្យរដ្ឋបាលថ្នាក់មូលដ្ឋាន ក៏ប៉ុន្តែរដ្ឋបាលមូលដ្ឋាន ត្រូវធ្វើរបាយការណ៍ទៅឱ្យរដ្ឋបាលថ្នាក់កណ្តាលជាប្រចាំ។ ឃុំ សង្កាត់នីមួយៗមានក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជារាស្ត្រនៃឃុំ-សង្កាត់ របស់ខ្លួនតាមការបោះឆ្នោតជាសាកល ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ ដោយសម្ងាត់ ស្របតាមនីតិវិធីនៃច្បាប់នៃច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់។




តារាងទី ៣ ៖ រចនាសម្ពន្ធរដ្ឋបាលឃុំ-សង្កាត់

ក្រុមប្រឹក្សានីមួយៗមានសមាជិកពី ៥ ទៅ ១១រូប ផ្អែកតាមប្រជាសាស្ត្រ និងភូមិសាស្ត្ររបស់ខ្លួន ហើយក្រុមប្រឹក្សានេះតម្រូវឲ្យជ្រើសរើសសមាជិកណាម្នាក់ ធ្វើជាប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់។ សមាជិកនៃក្រុមប្រឹក្សា

ឃុំ-សង្កាត់មានអាណត្តិ ៥ឆ្នាំ។ ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ គឺជាមេឃុំចៅ-សង្កាត់។ មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការ និងគណៈកម្មការនានាដើម្បីផ្តល់យោបល់និងជួយកិច្ចការនានាតាមតម្រូវការចាំបាច់។

សរុបមកក្នុងដំណាក់កាលដំបូងនៃការរៀបចំរដ្ឋបាលសាធារណៈ កិច្ចការស្ទើរទាំងអស់ទៅប្រមូលផ្តុំ និងធ្វើការសំរេចចិត្តដោយរដ្ឋបាលកណ្តាល ឬរដ្ឋបាលរាជធានី ខេត្ត ក្រុង ជាថ្នាក់សម្រុះសម្រួលក្នុងពេលអនុវត្ត។ រាជធានី ខេត្ត ក្រុងចាត់ចែងគ្រប់គ្រងការងារថ្នាក់រដ្ឋបាលចម្រុះស្រុក-ខណ្ឌ តាមឋានានុក្រម។ រាយការណ៍ សំណើរសំណូមពរផ្សេងៗរបស់គ្រប់ថ្នាក់រដ្ឋបាល ត្រូវបានបញ្ជូនតាមលំដាប់លំដោយពីថ្នាក់រដ្ឋបាលក្រោមបំផុតមកសុំការសម្រេចចុងក្រោយនៅរដ្ឋបាលថ្នាក់កណ្តាល។ អាជ្ញាធរមូលដ្ឋាន ដែលជាអភិបាល រាជធានី ខេត្ត ក្រុង និងប្រធានមន្ទីរ ជាតំណាងឱ្យរដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័ននៅថ្នាក់កណ្តាលផងដែរ។ ក្នុងតួនាទីនេះអាជ្ញាធរមូលដ្ឋាន រាជធានី ខេត្ត ក្រុង ត្រូវទទួលខុសត្រូវចំពោះរដ្ឋមន្ត្រី និងក្រសួងស្ថាប័ននានាក្នុងការសម្របសម្រួលជំនួយដឹកនាំវិស័យនានានៅតាម រាជធានី ខេត្ត ក្រុង ទៅថាសមត្ថកិច្ច ដែលបានរំលែកឱ្យ។

ផ្អែកតាមសមត្ថកិច្ចដែលបានរំលែកឲ្យនេះអភិបាលរាជធានី ខេត្ត-ក្រុង និងប្រធានមន្ទីរ អាចធ្វើទំនាក់ទំនងការងារ ដោយផ្ទាល់ជាមួយក្រសួងស្ថាប័ននានា នៅថ្នាក់កណ្តាល រួចធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬក្រសួងស្ថាប័ននៅថ្នាក់កណ្តាល ឱ្យកោះអញ្ជើញអភិបាល រាជធានី ខេត្ត-ក្រុង និងប្រធានមន្ទីរ មកជុំប្រជុំពិភាក្សា ឬសំណូមពរឲ្យអភិបាល រាជធានី ខេត្ត ក្រុង និងប្រធានមន្ទីរ បញ្ជាក់អំពីការអភិវឌ្ឍជាវិជ្ជមាន ឬអវិជ្ជមាននៃវិស័យជំនាញ ដែលរំលែកសមត្ថកិច្ចរាជធានី ខេត្ត-ក្រុង។

ក្រសួងស្ថាប័ននៅថ្នាក់កណ្តាល ធ្វើការគ្រប់គ្រងវិស័យជំនាញរបស់ខ្លួនស្ទើរគ្រប់ផ្អែកតាំងពីថ្នាក់កណ្តាលរហូតដល់ថ្នាក់មូលដ្ឋាន ឆ្លងតាមមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ខ្លួនតាមថ្នាក់រដ្ឋបាលដែនដី។ មន្ទីរ អង្គភាពទាំងនេះធ្វើរបាយការណ៍ លើកសំណើ ឬសំណូមពរផ្សេងៗជូនប្រធានស្ថាប័នសាមី ដោយត្រង់ ឬតាមរយៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។




តារាងទី ៤ ៖ រចនាសម្ពន្ធនៃរដ្ឋបាលព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី៣

## របកគំហើញនៃយន្តការថ្មីក្នុងការគ្រប់គ្រងរដ្ឋបាលដែនដី (ក្រុង ស្រុក ខណ្ឌ)

មុនកំណែទម្រង់ឆ្នាំ២០២០ ប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ មិនទាន់មានលក្ខណៈជារដ្ឋបាលឯកភាព ដែលជាការប្រមូលផ្តុំកម្លាំង រដ្ឋបាល ផែនការ និងថវិកា ដើម្បីចាត់ការអនុវត្តក្រោមឆ័ត្រតែមួយរបស់ក្រុមប្រឹក្សា ដែលកើតចេញពីការបោះឆ្នោត។ ជារួមរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានលក្ខណៈដាច់ដោយឡែកពីគ្នា នៅក្រោមរដ្ឋបាលស្រុកមានការិយាល័យជំនាញជាច្រើនដូចជា អប់រំ សុខាភិបាល សាធារណការ កសិកម្ម បរិស្ថាន អភិវឌ្ឍន៍ជនបទ សង្គមកិច្ច ជាដើម។ ក៏ប៉ុន្តែការិយាល័យជំនាញទាំងអស់នេះ មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នោះទេតែស្ថិតនៅក្រោមការគ្រប់គ្រងខ្សែបណ្តោយរបស់ក្រសួងដែលមានថវិកាដោយឡែករៀងៗខ្លួន។ ការិយាល័យជំនាញ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ធ្វើទំនាក់ទំនងរបស់ខ្លួនតាមខ្សែទទឹង តាមរយៈការគាំពារ ជួយជំរុញ ជួយសម្រួល ហើយការិយាល័យទាំងអស់នោះ មិនតែងតាំង មិនជ្រើសរើសមន្ត្រី មិនគ្រប់គ្រង មិនផ្តល់ប្រាក់បៀវត្ស ពីថ្នាក់ក្រុង ស្រុក ខណ្ឌនោះទេ។ បែបនេះហើយទើបបានជាគ្មានភាពប្រមូលផ្តុំ គំនិត ថវិការ ផែនការ សកម្មភាព ។ល។

## ៣.១ ក្រុមប្រឹក្សា

### ៣.១.១ <u>តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា</u>

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារដែលបានប្រគល់ និង/ឬដែលបានធ្វើប្រតិភូកម្ម ដោយមានភារកិច្ចសំខាន់ៗដូចជា ការងាររៀបចំកិច្ចប្រជុំក្រុមប្រឹក្សា ការងាររៀបចំបទបញ្ជាផ្ទៃក្នុង ការងាររៀបចំវិធានគ្រប់គ្រងផ្ទៃក្នុង ការងារដាក់ចេញដីកា និងសេចក្តីសម្រេចការងាររៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ការងារផែនការអភិវឌ្ឍប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ការអនុវត្តមុខងារ ការងារគ្រប់គ្រងបុគ្គលិក ការងារគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ។

### ៣.១.២ <u>សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា</u>

ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិ។ ក្រុមប្រឹក្សាប្រើប្រាស់អំណាចប្បញ្ញត្តិ ដោយការធ្វើដីកា និងប្រើប្រាស់អំណាចប្រតិបត្តិ តាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ស្របតាមក្របខណ្ឌដែលកំណត់ដោយច្បាប់ និងលិខិត បទដ្ឋានគតិយុត្តនានា។ ដីកា គឺជាវិធានការខាងផ្លូវច្បាប់ដែលបានអនុម័តដោយក្រុមប្រឹក្សាហើយដែលត្រូវអនុវត្ត។

ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាអាចស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតអភិបាល អភិបាលរងចេញពីមុខតំណែង ក្នុងករណីអភិបាល អភិបាលរងនោះមានករណីណាមួយដូចជា

បាត់បង់លក្ខណសម្បត្តិជាអភិបាល អភិបាលរង អសមត្ថភាព បំពេញការងារ មិនបានល្អ មានបញ្ហាសុខភាព ឬ បាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមាន សមត្ថកិច្ច បោះបង់ចោលការងារ និងប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ។

**៣.១.៣ <u>ការជ្រើសរើសក្រុមប្រឹក្សា</u>**

**ក. ការបោះឆ្នោត៖** ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតអសកល ដែលការបោះឆ្នោតនេះត្រូវស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ខ. អាណត្តិ៖** មានអាណត្តិ ប្រាំ(០៥)ឆ្នាំ ហើយផុតនៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ អាណត្តិរបស់ក្រុមប្រឹក្សាគឺគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រហូតដល់ថ្ងៃបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាថ្មី។

**៣.១.៤ <u>លក្ខណសម្បត្តិ</u>**

ដើម្បីក្លាយជាបេក្ខជនដែលអាចឈរឈ្មោះបោះឆ្នោតជ្រើសរើសជាក្រុមប្រឹក្សា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណសម្បត្តិដូចជា មានសញ្ជាតិខ្មែរពីកំណើត មានអាយុយ៉ាងតិចម្ភៃប្រាំ (២៥) ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោតមានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតក្រុមប្រឹក្សា។

**<u>សមាជិកក្រុមប្រឹក្សា</u>៖** ក្រុមប្រឹក្សាត្រូវមានប្រធានមួយរូប ដែលប្រធានក្រុមប្រឹក្សា គឺជាបេក្ខជនដែលមានលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សា។ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានសមាជិកចំនួនពីដប់មួយ (១១)រូប ទៅដល់ម្ភៃមួយ (២១)រូប។

**៣.១.៥ <u>ការបាត់បង់សមាជិកភាព</u>**

ការបាត់បង់សមាជិករបស់ក្រុមប្រឹក្សាអាចកើតឡើងក្នុងករណីដូចខាងក្រោម៖

- សាមីខ្លួនបាត់បង់លក្ខណសម្បត្តិ និងលក្ខខណ្ឌ សម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា
- សាមីខ្លួនសុំលាឈប់ពីក្រុមប្រឹក្សា តាមការដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរទៅប្រធានក្រុមប្រឹក្សា
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នាចាប់ពីពីរ (០២) ដងឡើងទៅដោយគ្មានច្បាប់អនុញ្ញាត

- សាមីខ្លួនត្រូវបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា អនុលោមតាមច្បាប់នីតិវិធី ឬបទបញ្ជាផ្ទៃក្នុង ឬក្រមសីលធម៌របស់ក្រុមប្រឹក្សា
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។

## ៣.២ គណៈអភិបាល

### ៣.២.១ តួនាទីនិងភារកិច្ចរបស់គណៈអភិបាល

គណៈអភិបាលមានតួនាទីជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ ក្រៅពីនេះ អភិបាលក៏មានតួនាទីតំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នក្នុងដែនសមត្ថកិច្ចរបស់ស្រុកផងដែរ។

ក្នុងនាមជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈអភិបាលមានភារកិច្ចសំខាន់ៗដូចជា៖

- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា
- លើកយោបល់ជូនក្រុមប្រឹក្សាពាក់ព័ន្ធកិច្ចការនានាដែលក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុវត្ត
- ផ្តួចផ្តើមរៀបចំ និងដាក់ជូនក្រុមប្រឹក្សានូវសេចក្តីព្រាងដីកាសេចក្តីសម្រេច និង បទប្បញ្ញត្តិនានាដើម្បីក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- ធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ការអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥) ឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល ថវិកានិងសកម្មភាពផ្តល់សេវាកម្មនានារបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ព្រមទាំងការអនុវត្តគម្រោង និងកម្មវិធីនានា។

ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនអភិបាលត្រូវ៖

- មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័ននានា និងធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា។
- ដឹកនាំសម្របសម្រួលការិយាល័យអង្គភាពពាក់ព័ន្ធនឹងរដ្ឋបាលឃុំសង្កាត់ដើម្បីធានារក្សា សន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈការអនុវត្តច្បាប់ និងការការពារសិទ្ធិមនុស្ស ក្នុងនាមជាប្រធានគណៈបញ្ជាការឯកភាព។
- ណែនាំសម្របសម្រួលតម្រង់ទិស ដល់ការិយាល័យអង្គភាព និងទីភ្នាក់ងារនានារបស់ ក្រសួងស្ថាប័នដែលមានប្រតិបត្តិការនៅក្នុងក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនៅមូលដ្ឋាន។
- ការតែងតាំង ការផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងរដ្ឋបាលស្រុក។

### ៣.២.២ សិទ្ធិអំណាចរបស់គណៈអភិបាល

គណៈអភិបាលមានសិទ្ធិអំណាចដូចខាងក្រោម៖

- បញ្ចេញមតិយោបល់ក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ប៉ុន្តែមិនអាចធ្វើការបោះឆ្នោតបានឡើយ
- ចុះហត្ថលេខាលើលិខិតបទដ្ឋាន និងលិខិតរដ្ឋបាលនានាសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ និងការងារចាំបាច់ផ្សេងៗទៀត ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាលើកលែង តែលិខិតបទដ្ឋានទាំងឡាយណា ដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សា
- ផ្តួចផ្តើមលើកសំណើ ក្រុមប្រឹក្សារបស់ខ្លួនដើម្បីដាក់ចេញនូវសេចក្តីសម្រេចខាងប្បញ្ញត្តិ ឬសេចក្តីសម្រេចខាងប្បញ្ញត្តិ
- លើកសំណើបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានា
- មួយចំនួនពាក់ព័ន្ធនឹងការងារគ្រប់គ្រងបុគ្គល ដែលមិនតម្រូវឲ្យមានការអនុម័តដោយក្រុមប្រឹក្សា។

ការសម្រេចឬការអនុវត្តកិច្ចការណាមួយរបស់គណៈអភិបាល ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាហើយពុំទទួលបានសេចក្តីសម្រេចពីក្រុមប្រឹក្សា ការសម្រេច ឬការអនុវត្តកិច្ចការនោះ ពុំមានសុពលភាពឡើយ។ ក្នុងករណីនេះគណៈអភិបាល (អភិបាល ឬអភិបាលរង) ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីសេចក្តីសម្រេច ឬសកម្មភាពទាំងនោះ។

គណៈអភិបាលអាចសម្រេច ឬអនុវត្តកិច្ចការណាមួយ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាដោយពុំចាំបាច់មានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាបាន ក្នុងក្របខណ្ឌនៃអំណាចដែលខ្លួនទទួលបានពីការធ្វើប្រតិភូកម្មពីក្រុមប្រឹក្សា ឬក្នុងករណីប្រធានស័ក្តិ ក្នុងករណីនេះគណៈអភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាអំពីកិច្ចការទាំងនោះ។

### ៣.២.៣ ការជ្រើសរើសគណៈអភិបាល

គណៈអភិបាលក្រុងស្រុកខណ្ឌមានចំនួនចាប់ពីបី(៣)រូប ទៅប្រាំ(៥)រូប។ អភិបាល ក្រុង ស្រុក ខណ្ឌ ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ចំពោះ អភិបាលរងក្រុង ស្រុក ខណ្ឌ ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាល អភិបាលរងមានអាណត្តិការងារមិនលើសពីបួន (៤) ឆ្នាំនឹងអាចត្រូវតែងតាំងបានបួន (៤)ឆ្នាំទៀតសម្រាប់អាណត្តិទីពីររបស់ខ្លួនក្នុងដែនសមត្ថកិច្ចដដែល។

### ៣.២.៤ លក្ខណសម្បត្តិ

អភិបាលត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការស៊ីវិលទាំងពីរភេទដែលស្ថិតក្នុងក្របខណ្ឌ មន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ឬក្រៅក្របខណ្ឌក្រសួងមហាផ្ទៃនិងត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានឋានន្តរស័ក្តិចាប់ពីអនុមន្ត្រីឡើង
- មានអាយុចាប់ពីសាមសិប (៣០) ឆ្នាំឡើងគិតដល់ថ្ងៃតែងតាំង
- មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចប្រាំ (៥)ឆ្នាំ ឬ/និង មានសញ្ញាបត្រ បរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំយុវជននិងកីឡា
- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬមជ្ឈិមណាមួយ។

ដោយឡែក អភិបាលរង ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដោយជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការស៊ីវិលទាំងពីរភេទ ដែលស្ថិតក្នុងក្របខណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ឬក្រៅក្របខណ្ឌក្រសួងមហាផ្ទៃ និងត្រូវមានលក្ខណសម្បត្តិដូចខាងក្រោមៈ

- មានឋានន្តរស័ក្តិចាប់ពីនាយក្រមការឡើង
- មានអាយុចាប់ពីម្ភៃប្រាំ (២៥) ឆ្នាំ ឡើងគិតដល់ថ្ងៃតែងតាំង
- មានបទពិសោធន៍ការងារផ្នែករដ្ឋបាលយ៉ាងតិចបី (៣) ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្ររងដែលទទួលស្គាល់ដោយក្រសួងអប់រំយុវជននិងកីឡា
- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬមជ្ឈិមណាមួយ។

## ៣.៣ នាយករដ្ឋបាល

### ៣.៣.១ ការតែងតាំងនាយករដ្ឋបាល

នាយករដ្ឋបាល ត្រូវបានប្រកាសដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលដោយយោងតាមការសម្រេចរបស់ក្រុមប្រឹក្សា។ នាយករដ្ឋបាល ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រី ដែលស្ថិតក្នុងឋានន្តរស័ក្តិចាប់ពីក្រមការដើមខ្សែនៃក្របខណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។

### ៣.៣.២ តួនាទី និងភារកិច្ចរបស់នាយករដ្ឋបាល

នាយករដ្ឋបាលមានតួនាទី និងភារកិច្ចដូចខាងក្រោមៈ

ក. ជាជំនួយការដល់ក្រុមប្រឹក្សាគណៈអភិបាល និងអភិបាល ក្នុងការចាត់ចែងការងាររដ្ឋបាល និងការងារនានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្តតួនាទីនេះនាយករដ្ឋបាលត្រូវៈ

- ធ្វើរបាយការណ៍ និងត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាល អភិបាល និង ក្រុមប្រឹក្សារបស់ខ្លួន

- រៀបចំ និងដាក់ជូននៅគណៈអភិបាលពិនិត្យសម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាក្រុង ស្រុក ខណ្ឌ ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលហើយត្រូវធានាថាកិច្ចការទាំងនោះត្រូវបានរៀបចំឡើងស្របច្បាប់លិខិតបទដ្ឋានគតិយុត្តនានា និងទម្រង់បែបបទ នៃលិខិតស្នាមរដ្ឋបាល
- រៀបចំ និងដាក់ជូនគណៈអភិបាលនូវវិធានការ និងគោលការណ៍ក្នុងការអនុវត្តដីកានិងសេចក្តីសម្រេច នានាក្នុងក្រុមប្រឹក្សា
- ធ្វើជាសេនាធិការជូនអភិបាល និងប្រធានក្រុមប្រឹក្សាក្នុងការត្រៀមរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សារួមទាំងសេចក្តីសម្របសម្រួល ក្នុងការរៀបចំឯកសារ និងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗ នៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន។ ឯកសារ និងខ្លឹមសារទាំងអស់ ដែលនាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ បានរៀបចំសម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សា ត្រូវដាក់ជូនគណៈអភិបាលដើម្បីពិនិត្យ និងផ្តល់យោបល់ជាមុនតែមានការកំណត់ផ្សេងដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា៖
  - ធ្វើជាសេនាធិការជូនក្រុមប្រឹក្សា ក្នុងការរៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំ ក្នុងការរៀបទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា
  - ត្រៀមរៀបចំកិច្ចការនានា សម្រាប់បម្រើឱ្យកិច្ចប្រជុំទាំងអស់របស់គណៈអភិបាល តាមការណែនាំរបស់អភិបាល
  - ធានាក្នុងការទទួល និងបែងចែកលិខិតស្នាមឯកសារនានាឲ្យបានត្រឹមត្រូវ ដល់សមាជិកក្រុមប្រឹក្សា អភិបាល អភិបាលរង ព្រមទាំងក្រសួងស្ថាប័ន មន្ទីរ អង្គភាព និងការិយាល័យ និងអ្នកពាក់ព័ន្ធនានា
  - គ្រប់គ្រង និងប្រើប្រាស់ត្រារដ្ឋបាលឱ្យបានត្រឹមត្រូវតាមការកំណត់
  - ធានារក្សាទុកដាក់ឱ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារលិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សា និងគណៈអភិបាល និងរដ្ឋបាលរបស់ខ្លួន
  - បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សា គណៈអភិបាល អភិបាល ឬដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

ខ. មានសិទ្ធិចូលរួម និងបញ្ចេញយោបល់ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាកិច្ចប្រជុំគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សា និងកិច្ចប្រជុំ និងក្នុងកិច្ចប្រជុំគណៈអភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ លើកលែងតែនាយករដ្ឋបាលជាសមាជិកគណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងារណាមួយ។

គ. ក្នុងការចូលរួមក្នុងកិច្ចប្រជុំ និងការអនុវត្តការងារប្រចាំថ្ងៃនាយករដ្ឋបាល ដែលអាចផ្តល់យោបល់ដល់ក្រុមប្រឹក្សាគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួនអំពីបញ្ហាច្បាប់និងបច្ចេកទេស ដើម្បីធានាសេចក្តីសម្រេច និងសកម្មភាពនានារបស់ក្រុមប្រឹក្សាគណៈអភិបាល និងអភិបាលមានលក្ខណៈសមស្របតាមរដ្ឋធម្មនុញ្ញច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបទដ្ឋានជាតិសម្រាប់សុវត្ថិភាព និងគុណភាពដែលបានកំណត់ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងសាលាក្រុង សាលាស្រុក និងសាលាខណ្ឌ។

ឃ. ត្រូវធានាឱ្យការិយាល័យ មន្ត្រី បុគ្គលិកទាំងអស់អនុវត្តការងារបានត្រឹមត្រូវទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនិងនីតិវិធីនានា និងតាមការសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។

គណៈអភិបាល និងអភិបាលអាចធ្វើប្រតិភូកម្មដល់នាយករដ្ឋបាលឲ្យលើកយោបល់លើកិច្ចការណាមួយ ដែលស្ថិតក្នុងវិសាលភាពនៃតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីគណៈអភិបាលឬអភិបាលពិនិត្យសម្រេចតាមការចាំបាច់។

## ៣.៤ អង្គភាពរបស់ក្រុមប្រឹក្សា

ការិយាល័យបច្ចេកទេស មុនអនុវត្តតាមអនុក្រឹត្យ គេឃើញថាការិយាល័យទាំងនោះស្ថិតនៅក្រោមការគ្រប់គ្រងតាមខ្សែបណ្តាញរបស់ក្រសួងស្ថាប័នជំនាញនីមួយៗរបស់ខ្លួន។ ឧទាហរណ៍ក្នុងការិយាល័យអប់រំ បុគ្គលិករបស់ការិយាល័យនេះ ជាបុគ្គលិករបស់ក្រសួងអប់រំ ដែលមានតួនាទី និងទំនួលខុសត្រូវពីក្រសួងអប់រំ។

នៅក្នុងរចនាសម្ពន្ធថ្មី ការអនុវត្តរបៀបគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានធ្វើឡើងឱ្យទូលំទូលាយជាងមុន ដោយការិយាល័យជំនាញដែលមាននៅក្រោមថ្នាក់ ក្រុង ស្រុក ខណ្ឌ ដែលពីមុនមានទំនួលខុសត្រូវនៅចំពោះមុខក្រសួងជំនាញ ត្រូវបានច្របាច់បញ្ចូល និងរៀបចំឱ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋបាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។ ការធ្វើកំណែទម្រង់នេះ សំដៅទៅដល់ការធ្វើសហត្ថិភាពស៊ីជម្រៅជាងមុន ដោយមានការផ្ទេរនូវមុខងារ ធនធាន ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រោះរដ្ឋបាលថ្នាក់ក្រោមជាតិជាអ្នកដែលស្ថិតនៅជិតប្រជាពលរដ្ឋបំផុត ដែលនេះជាកត្តាជំរុញឱ្យការផ្តល់សេវាទាន់ពេលវេលា ហើយឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងតម្រូវការក្នុងមូលដ្ឋាន។

### ៣.៤.១ <u>ការិយាល័យនិងអង្គភាពចំណុះទាំង៥ របស់ក្រុង ស្រុក ខណ្ឌ និងការិយាល័យជំនាញ ទាំង២០</u>

មុនមានកំណែទម្រង់រចនាសម្ពន្ធក្រុង ស្រុក ខណ្ឌ រដ្ឋបាលក្រុង ស្រុក ខណ្ឌ មាន ការិយាល័យ និងអង្គភាពចំណុះចំនួន៥នៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ការិយាល័យទាំង៥នោះរួមមាន ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ផែនការ និងគាំទ្រឃុំ-សង្កាត់ អង្គភាពលទ្ធកម្ម ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យអន្តរវិស័យ។ ចំណែកការិយាល័យជំនាញទាំង២០មានដូចជា ការិយាល័យព័ត៌មាននៃក្រសួងព័ត៌មាន ការិយាល័យផែនការស្ថិតិនៃក្រសួងផែនការ មណ្ឌលសេវាកម្មនៃក្រសួងយុត្តិធម៌ ការិយាល័យអប់រំយុវជន និងកីឡានៃក្រសួង

អប់រំយុវជន និងកីឡា ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាល នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ការិយាល័យពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ការិយាល័យអភិវឌ្ឍន៍ជនបទនៃក្រសួងអភិវឌ្ឍជនបទ ការិយាល័យសាធារណការនៃក្រសួង សាធារណការនិងដឹកជញ្ជូន ការិយាល័យឧស្សាហកម្មនិងសិប្បកម្មនៃក្រសួងឧស្សាហកម្មនិង សិប្បកម្ម ការិយាល័យរ៉ែនិងថាមពលនៃក្រសួងរ៉ែនិងថាមពល ការិយាល័យទេសចរណ៍នៃក្រសួងទេសចរណ៍ ការិយាល័យប្រៃសណីយ៍និងទូរគមនាគមន៍នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ការិយាល័យសង្គមកិច្ចនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការិយាល័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ការិយាល័យកិច្ចការនារីនៃក្រសួងកិច្ចការនារី ការិយាល័យធម្មការនិងសាសនានៃក្រសួងធម្មការនិងសាសនា ការិយាល័យ វប្បធម៌និងវិចិត្រសិល្បៈនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ការិយាល័យកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការិយាល័យបរិស្ថាននៃក្រសួងបរិស្ថាន និងការិយាល័យធនធានទឹកនិង ឧតុនិយមនៃក្រសួងធនធានទឹកនិងឧតុនិយម។

### ៣.៤.២ ការិយាល័យទាំង១៣ ក្នុងរចនាសម្ពន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ការិយាល័យនិងអង្គភាពចំណុះទាំង៥ ដែលនៅក្រោមរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការិយាល័យជំនាញទាំង២០ របស់ក្រសួងត្រូវបានរួមបញ្ចូលគ្នាចេញជាការិយាល័យចំនួន១៣វិញ។ ការិយាល័យទាំង១៣នេះមាន ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង ការិយាល័យគ្រប់គ្រងធនធានមនុស្ស ការិយាល័យលេខាធិការក្រុមប្រឹក្សា ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ការិយាល័យផែនការ និងគាំទ្រឃុំសង្កាត់ ការិយាល័យនីតិកម្មសម្រុះសម្រួលវិវាទមូលដ្ឋាន ការិយាល័យអប់រំ យុវជន និងកីឡា ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល អង្គភាពលទ្ធកម្ម ការិយាល័យច្រកចេញចូលតែមួយ ការិយាល័យសេដ្ឋកិច្ច ការិយាល័យសង្គមកិច្ច និងការិយាល័យ កសិកម្ម ធនធានធម្មជាតិនិងបរិស្ថាន។




តារាងទី ៥ ៖ រចនាសម្ព័ន្ធថ្មីរដ្ឋបាលក្រុង-ស្រុក




តារាងទី ៦ ៖ រចនាសម្ពន្ធថ្មីរដ្ឋបាលខណ្ឌ នៃរាជធានីភ្នំពេញ

## ៣.៥ បុគ្គលិក

បុគ្គលិករបស់ក្រុមប្រឹក្សា គឺជាមន្ត្រីរាជការស៊ីវិលនិងជាបុគ្គលិកដែលមិនមែនជាមន្ត្រីរាជការស៊ីវិលក្នុងនោះរួមមាន៖

ក. បុគ្គលិកដែលត្រូវបានជ្រើសរើស និងតែងតាំងដោយក្រុមប្រឹក្សា នៅពេលមានតម្រូវការធនធានមនុស្ស។

ខ. បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញ និងផ្ទេរទៅឱ្យក្រុមប្រឹក្សា ក្នុងនោះរួមមាន៖

- បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញតាមការធ្វើសមាហរណកម្មរចនាសម្ពន្ធ និងមន្ត្រីរាជការដែលមានបច្ចុប្បន្នទៅក្នុងរចនាសម្ពន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- បុគ្គលិកដែលបានផ្ទេរពីក្រសួងស្ថាប័នទៅឱ្យក្រុមប្រឹក្សា តាមរយៈកិច្ចដំណើរការនៃការផ្ទេរមុខងារនិងធនធាន។

គ. បុគ្គលិកដែលត្រូវបានតែងតាំងដោយរដ្ឋាភិបាល ក្រសួង ស្ថាប័នថ្នាក់ជាតិឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សាស្របតាមលិខិតបទដ្ឋាន។

បុគ្គលិកដែលមិនមែនជាមន្ត្រីរាជការស៊ីវិលរួមមាន មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកបណ្ដោះ និងទីប្រឹក្សាបច្ចេកទេសដែលជ្រើសរើស និងចុះកិច្ចសន្យាជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ជួយការងារដល់ការិយាល័យ អង្គភាពនានានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

សមាជិកក្រុមប្រឹក្សាមិនមែនជាបុគ្គលិករបស់ក្រុមប្រឹក្សាទេ។

បុគ្គលិកក្រុមប្រឹក្សាមិនរាប់បញ្ចូលមន្ត្រីនៃក្រសួងស្ថាប័ន មន្ទីរអង្គភាពនានារបស់រាជរដ្ឋាភិបាល មន្ត្រីដទៃទៀតដែលអនុវត្តភារកិច្ចពាក់ព័ន្ធសន្តិសុខ សណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្ស និងបុគ្គលិករបស់គម្រោងកម្មវិធីនានា ដែលបញ្ជូនឲ្យមកបំពេញការងារនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌឡើយ។

# ជំពូកទី៤
# បញ្ហាប្រឈម និងដំណោះស្រាយ

ជាក់ស្តែងការអនុវត្តគោលនយោបាយមានភាពស្មុគស្មាញ និងប្រឈមមុខជាមួយបញ្ហាដែលកំពុងកើតមាន មុននឹងអាចធ្វើឱ្យកំណែទម្រង់មានភាពរលូន។ យោងតាមប្រសាសន៍របស់លោក ជ័យ សម្បត្តិផល្លា ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប បានបង្ហាញនូវមូលហេតុជាច្រើនដែលជំរុញឱ្យមាននូវសមាហរណកម្មរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ បញ្ហាទី១ គឺនៅក្នុង ក្រុង ស្រុក ខណ្ឌនីមួយៗ ជាមធ្យមមានការិយាល័យជំនាញចំនួន ៦-៩ ការិយាល័យ ដូច្នេះហើយ ក្នុងក្រុង ស្រុក ខណ្ឌ មួយចំនួនបើទោះបីជាមានឈ្មោះនៃការិយាល័យជំនាញមាននៅក្នុងរចនាសម្ពន្ធរបស់ក្រសួងសាមី នៅតាមបណ្តាក្រុង ស្រុក ខណ្ឌ ក៏ដោយក៏ខ្លះមិនមាននូវវត្តមានពិតប្រាកដរបស់ការិយាល័យជំនាញទាំងនោះ នៅតាមសាលាក្រុង ស្រុក ខណ្ឌ នោះទេ។ ទី២ ការិយាល័យជំនាញខ្លះមានតែម្នាក់ ឬពីរនាក់ ជាហេតុនាំបណ្តាលឱ្យការអនុវត្តការងារ និងការផ្តល់សេវាគ្មានប្រសិទ្ធភាព។ ទី៣ បុគ្គលិកនៃការិយាល័យជំនាញខ្លះ បែរជាគ្មានសូម្បីតែការិយាល័យក្នុងក្រុង ស្រុក ខណ្ឌ ទៀតផង ដូចនេះគាត់ត្រូវធ្វើរខ្លួនទៅនឹងថ្នាក់ក្រោមជាតិ ឬកន្លែងផ្សេងៗ ឧទាហរណ៍ការិយាល័យនៃក្រសួងធម្មការ បានទៅសុំជ្រកកោនជាមួយនឹងវត្តអារាមជាដើម។ ទី៤ ការអនុវត្តការងាររបស់មន្រ្តីជំនាញមិនមានភាពសកម្មក្នុងការបង្ការ និងដោះស្រាយបញ្ហាដែលកើតមានក្នុងសហគមន៍ ដោយពួកគាត់គ្រាន់តែរង់ចាំសេចក្តីណែនាំ ពីក្រសួងសាមី តែប៉ុណ្ណោះ។ ទី៥ ការធ្វើសមាហរណកម្មរដ្ឋបាលថ្នាក់មូលដ្ឋាន ក្រុង ស្រុក ខណ្ឌ អាចចូលរួមចំណែកក្នុងការកាត់បន្ថយនូវចំណាយ តាមរយៈការរួមបញ្ចូលការិយាល័យទៅតាមវិស័យនីមួយៗ ដោយមិនចាំបាច់បង្កើតការិយាល័យបន្ថែម ឱ្យសមាមាត្រនឹងចំនួនក្រសួងជំនាញដែលនាំឱ្យបន្ទុករបស់រដ្ឋកាន់តែធំ តែគ្រាន់តែមានការរៀបចំទៅតាមវិស័យវិញ។ ឧទាហរណ៍ ការរួមបញ្ចូលនៃការិយាល័យសង្គមកិច្ចជាដើម ធ្វើឱ្យចំណាយរបស់រដ្ឋអាចកាត់បន្ថយ រក្សាដដែល ឬកើនឡើងតិចតួច។ ទី៦ សមាហរណកម្មការិយាល័យជំនាញអាចកាត់បន្ថយចំនួនមនុស្សបានច្រើន ស្របពេលដែលធនធានមនុស្សមានការខ្វះខាត។

## ៤.១ បញ្ហាប្រឈម

អំឡុងពេលអនុវត្តគោលនយោបាយសមាហរណកម្មក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋាភិបាលកម្ពុជាជួបប្រទះ នូវបញ្ហាធំៗចំនួន ៤គឺ៖

- <u>បញ្ហាក្នុងការផ្លាស់ប្តូរនៃរបៀបរបបការងារ ផ្នត់គំនិត និងមុខងារ</u> ៖ ការផ្លាស់ប្តូររបៀបរបបការងារភ្លាមៗតែងធ្វើឱ្យការសម្រួលរបស់មន្រ្តីរាជការ មានភាពលំបាកក្នុងរយៈពេលខ្លី។ ការប្រតិបត្តិការងារ ក្នុងរបៀបរបបថ្មី ប្រឈមទៅនឹងការប្រតិកម្មពីមន្រ្តីរាជការ ដោយហេតុថាការកែប្រែនេះបានជះឥទ្ធិពលដោយផ្ទាល់ទៅលើលទ្ធផលការងាររបស់ពួកគេ ព្រោះមុនពេលមានកំណែទម្រង់ពួកគេស្ថិតក្នុងស្ថានភាពសម

តុល្យមួយរវាងការងារ និងឋានានុក្រម តែដោយសារតែមាននូវការកែប្រែថ្មី ធ្វើឱ្យមានភាពស្មុគស្មាញរវាង ទំនាក់ទំនងការងារ របៀបរបបការងារ និងឋានានុក្រមថ្មី។ ម្យ៉ាងវិញទៀត ការកែប្រែនេះទៀតសោត មិន ត្រឹមតែព្យាយាមកំណែទម្រង់តែឋានានុក្រម និងការប្រព្រឹត្តទៅនៃការប្រតិបត្តិការងារប៉ុណ្ណោះទេ ក៏ ព្យាយាមផងដែរកែប្រែនូវផ្នត់គំនិតនៃការធ្វើការងាររបស់មន្ត្រីជំនាញថ្នាក់ក្រោមជាតិ ក្រុង ស្រុក ខណ្ឌ ដោយជំរុញឱ្យ មន្ត្រីមូលដ្ឋានសកម្មក្នុងការបង្ការ អភិវឌ្ឍន៍ និងដោះស្រាយបញ្ហាក្នុងក្រុង ស្រុក ខណ្ឌ របស់ខ្លួនប្រកបដោយ ប្រសិទ្ធភាព ជាជាងរង់ចាំតែសេចក្ដីណែនាំពីក្រសួងជំនាញ និងរដ្ឋបាលថ្នាក់ លើ។ មុខងារខ្លះមានភាពសុំាញ៉ាំដែលធ្វើឱ្យមានភាពលំបាកក្នុងការអនុវត្តជាក់ស្ដែង។

- <u>បញ្ហាក្នុងការផ្លាស់ប្ដូរតំណែង</u> ៖ កំណែទម្រង់តែងតែធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់បុគ្គលមួយ ចំនួន ដែលខ្លះជាផលវិជ្ជមាន អវិជ្ជមាន ច្រើន ឬតិច ទៅតាមការកែប្រែដែលកើតមានឡើងជាក់ស្ដែង។ ហេតុដូចនេះហើយ បានជាធ្វើឱ្យមានភាពមិនពេញចិត្តរវាង បុគ្គលិក មន្ត្រីរាជការដែលបម្រើការ ចំពោះ ការផ្លាស់ប្ដូរតំណែង និងមុខងារ។
- <u>ធនធានមនុស្ស</u> ៖ កំណែទម្រង់ត្រូវការចាំបាច់នូវធនធានមនុស្សតាមជំនាញដែលមានជំនាញ និង ចំណេះដឹងច្បាស់លាស់ ក្នុងការប្រតិបត្តិការងារឱ្យមានប្រសិទ្ធភាព និងសកម្ម ទៅតាមតម្រូវការរបស់ មូលដ្ឋាន ដោយមិនចាំបាច់រង់ចាំតែសេចក្ដីសម្រេចពីថ្នាក់លើ។
- <u>ថវិកាដែលជាបន្ទុករបស់រដ្ឋបាលថ្នាក់ ក្រុង ស្រុក ខណ្ឌ</u> ៖ ការធ្វើកំណែទម្រង់ត្រូវការចាំបាច់នូវថវិកា ភ្លាមៗដើម្បីដាក់ចេញជាសកម្មភាព តួយ៉ាងប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ សម្រាប់បុគ្គលិក ព្រមទាំង ចំណាយផ្សេងៗក្នុងក្រុង ស្រុក ខណ្ឌ ជាដើម។ ក៏ប៉ុន្តែ ជាក់ស្ដែងកញ្ចប់ថវិកាមានភាពតឹងរឹង និងមាន រយៈពេលយូរ ក្នុងការប្រគល់មក ក្រុង ស្រុក ខណ្ឌ ក្នុងការប្រតិបត្តិការងាររបស់ខ្លួន។ ជាក់ស្ដែង ការផ្ទេរ មុខងារ បានមកដល់មុនពេលដែលថវិកាមិនទាន់ផ្ទេរពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលទាំងនេះធ្វើឱ្យ ធ្លាក់មកជាបន្ទុករបស់រដ្ឋបាលក្រុង ស្រុង ខណ្ឌ។

## ៤.២ ដំណោះស្រាយ

ដើម្បីកាត់បន្ថយនូវបញ្ហាដែលកើតមានឡើងទាំងឡាយខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ ដំណោះស្រាយមួយចំនួនដូចខាងក្រោម៖

- ការរៀបចំមុខតំណែងថ្មី ប្រកបដោយភាពយុត្តិធម៌ ដោយការជ្រើសរើសប្រធានការិយាល័យ ត្រូវបាន ស្ថិតនៅក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ស្របទៅតាមការថ្លឹងថ្លែងទៅលើ គុណសម្បត្តិរបស់មន្ត្រីរាជការម្នាក់ៗ។

- ការធានារក្សាបាននូវអត្ថប្រយោជន៍នៃបុគ្គលិកដែលកំពុងកាន់តំណែង ដូចជាមុខតំណែង និងប្រាក់បៀវត្ស។
- ការផ្តល់នូវវគ្គបណ្តុះបណ្តាលពីក្រសួងជំនាញទៅដល់មន្ត្រីរាជការដើម្បីពង្រឹងសមត្ថភាព ក្នុងការអនុវត្តការងារ។
- រៀបចំលិខិតបទដ្ឋាន (ក្នុងកម្រិតប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ដើម្បីកំណត់ពីធនធានបន្ថែមពីថវិការដ្ឋ និងនីតិវិធីនៃការរៀបចំ និងអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់តែឆ្នាំ២០២១សិន ដើម្បីឱ្យក្រុង ស្រុក ខណ្ឌអាចមានការរៀបចំគម្រោងថវិការឆ្នាំ២០២១បានទាន់ពេលតាមប្រតិទិនកំណត់។
- ស្នើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគ្រោងបម្រុងថវិកាមួយចំនួនសមស្របសម្រាប់ផ្ទេរបន្ថែមទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌដោយរួមបញ្ចូលទាំងបន្ទុកបុគ្គលិក ចំណាយប្រតិបត្តិការរដ្ឋបាល និងសម្រាប់អនុវត្តមុខងារក្នុងវិស័យទាំង២០ សម្រាប់ឆ្នាំ២០២១។
- សម្រាប់ពីឆ្នាំ២០២២តទៅ ការផ្ទេរធនធានថវិកាបន្ថែមត្រូវរៀបចំទៅតាមបែបបទ នីតិវិធីដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យ។

# សេចក្តីសន្និដ្ឋាន

យោងតាមការស្រាវជ្រាវខាងលើនេះ យើងឃើញថាគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេសត្រូវផ្លាស់ប្តូររចនាសម្ពន្ធរបស់ខ្លួន។ ទោះបីជាចំនួនការិយាល័យត្រូវបានកាត់បន្ថយ ប៉ុន្តែកិច្ចការ និងមុខងារនៅតែរក្សាដដែល មិនតែប៉ុណ្ណោះចំនួនការិយាល័យតិចជាងមុន ក៏ផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រងផងដែរ។ ជាពិសេស ថ្នាក់ជាតិបានផ្តល់អំណាចថែមទៀតទៅដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយឱ្យការិយាល័យទាំងអស់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ នេះមានន័យថា រដ្ឋបាលក្រុង ស្រុក ខណ្ឌអាចធ្វើការងារកាន់តែងាយស្រួលជាងមុន។ រីឯបុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌនឹងទទួលបានការបណ្តុះបណ្តាលបន្ថែមដើម្បីធ្វើឱ្យដំណើរការថ្មីនេះទទួលបានជោគជ័យ។

ពេលកំណែទម្រង់រដ្ឋាភិបាលសម្រេចយករដ្ឋបាលក្រុង ស្រុក ខណ្ឌ ជារដ្ឋបាលធំមួយជាគោលដោយការិយាល័យជំនាញទាំងអស់ប្រែក្លាយជាអង្គភាពដែលចំណុះឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ក្រសួងទាំងអស់ ធ្វើការផ្ទេរកញ្ចប់ថវិការបស់ខ្លួនមកកាន់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យស្រុកមានកញ្ចប់ថវិការួមមួយ ក្នុងការអនុវត្តចាត់ចែងធ្វើការងារអន្តរវិស័យ។ ក្រោយការធ្វើសមាហរណកម្មការិយាល័យជំនាញ រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងមូល រួមមានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវមានគណនេយ្យភាពចំពោះមុខក្រសួងទាំងអស់។ ឯមន្ត្រីជំនាញទាំងអស់ដែលបានធ្វើសមាហរណកម្ម នៅតែមានភារកិច្ចនិងទទួលបន្ទុកទៅតាមជំនាញរបស់ខ្លួន ដោយគ្រាន់តែស្ថិតក្រោមចំណុះរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌវិញ ជំនួសឱ្យក្រសួងជំនាញ។ ពេលនេះយើងឃើញថារដ្ឋមន្ត្រីក្រសួងជំនាញធ្វើការបញ្ជាគាំទ្រទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងមូលមានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អភិបាលក្រុង ស្រុក ខណ្ឌ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងមូលត្រូវធ្វើគណនេយ្យភាពទៅក្រសួងនីមួយៗ ដូច្នេះហើយពេលមានបញ្ហាកសិកម្មកើតឡើង សត្វបំផ្លាញកសិផល ក្រុមប្រឹក្សាស្រុក អភិបាលស្រុកចេញមុខសម្របសម្រួល ដោះស្រាយនិងធ្វើអន្តរាគមន៍ តាមរយៈការប្រមូលកម្លាំងមន្ត្រីរបស់ខ្លួនដែលទទួលបន្ទុកកសិកម្មមកជួយដោះស្រាយ។

ស្របពេលនឹងមានកំណែទម្រង់ថ្មី បញ្ហាមួយចំនួនប្រាកដជាមានការលេចឡើង។ មន្ត្រីដែលបានប្រកាសរួចក្នុងរចនាសម្ពន្ធថ្មីមិនប្រាកដថាមានសមត្ថភាពអាចគ្រប់គ្រងនិងដឹកបំពេញមុខងាររបស់ខ្លួនបានល្អនោះទេ។ ម្យ៉ាងវិញទៀត រដ្ឋាភិបាលបានរៀបចំកញ្ចប់ថវិកាសម្រាប់កំណែទម្រង់មួយនេះ។ ប៉ុន្តែដោយសារ វាមានរយៈពេលខ្លីពេក ការរៀបចំគឺមិនមានភាពរហ័សទាន់នឹងការអនុវត្តនៃរចនាសម្ពន្ធថ្មីនោះទេ។

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ រួមទាំងការចុះសម្ភាសន៍ដោយផ្ទាល់ជាមួយមន្ត្រីជំនាញពាក់ព័ន្ធនឹងគោលនយោបាយនេះ ក្នុងនាមយើងខ្ញុំជាអ្នកស្រាវជ្រាវ យើងខ្ញុំពិតជាមានភាពសោមនស្សយ៉ាងក្រៃលែង ដោយពួកយើងបានធ្វើការស្វែងយល់ និងយល់កាន់តែច្បាស់ពីកំណែទម្រង់រចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ នេះ។ កំឡុងពេលស្រាវជ្រាវរហូតមកដល់ពេលបញ្ចប់ការស្រាវជ្រាវ ពួកយើងឃើញមានចំណុចខ្លះៗដែលមិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយ។ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍនិងលើកស្ទួយការដាក់ចេញនូវយន្តការថ្មីក្នុងការ គ្រប់គ្រងរដ្ឋបាលដែនដី យើងខ្ញុំសូមចូលរួមជាមតិយោបល់ និងគតិមួយចំនួនៈ

រដ្ឋាភិបាលគួររៀបចំ ក្រុមការងារដែលពាក់ព័ន្ធចុះទៅធ្វើការសិក្សា ពិនិត្យស្ថានភាពជាក់ស្ដែង ដើម្បីឱ្យដឹងថាតើរចនាសម្ព័ន្ធថ្មីនេះ សមស្របទៅនឹងទីកន្លែងនីមួយៗដែរឬក៏យ៉ាងណា។ មនុស្សនៅកន្លែងនីមួយៗអាចលើសឬក៏ខ្វះ ព្រោះនៅកន្លែងមិនដូចគ្នាទេ។ នៅពេលយើងរៀបចំលើសនោះការខាតបង់ប្រាកដជាកើតមានដោយសារកន្លែងផ្សេងទៀតមានការខ្វះខាត។

- ចំពោះមន្ត្រីដែលបានដាក់ទៅក្នុងរចនាសម្ព័ន្ធមិនប្រាកដថាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងនិងបំពេញមុខងារថ្មីនេះបានទេ។ ដូចនេះតម្រូវឱ្យក្រសួងរៀបចំការបណ្ដុះបណ្ដាលសមត្ថភាពទៅដល់មន្ត្រីបំពេញការងារទាំងអស់ ដើម្បីឱ្យពួកគាត់យល់កាន់តែច្បាស់ពីកិច្ចការដែលពួកគាត់ត្រូវបំពេញ។
- កញ្ចប់ថវិកាដែលត្រូវធ្លាក់មកយឺត ត្រូវពន្លឿនឱ្យទាន់ពេលវេលា ដើម្បីកុំឱ្យមានភាពយឺតយ៉ាវក្នុងការអនុវត្តការងារ។ ថវិកាពិតជាមានសារៈសំខាន់ណាស់សម្រាប់ធ្វើឱ្យកិច្ចការនេះមានដំណើរការទៅមុខ។
- មានការផ្សព្វផ្សាយជូនដល់មន្ត្រីពាក់ព័ន្ធ ទាក់ទងនឹងអត្ថប្រយោជន៍ មូលហេតុ គោលបំណង នៃកំណែទម្រង់ និងវិធីសាស្ត្រយ៉ាងណាធ្វើឱ្យកំណែទម្រង់ទទួលបានជោគជ័យ។
- ផ្ដល់ឱកាសឱ្យអ្នកជំនាន់ក្រោយ បានបញ្ចេញស្នាដៃក្នុងការចូលរួមចំណែកគោលនយោបាយថ្មីនេះ។

# ឯកសារយោង

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

អនុក្រឹត្យ

- អនុក្រឹត្យលេខ១៨២ អនក្រ ប.ក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ពន្ធរដ្ឋបាលក្រុង
- អនុក្រឹត្យលេខ១៨៣ អនក្រ ប.ក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ពន្ធរដ្ឋបាលខណ្ឌ
- អនុក្រឹត្យលេខ១៨៤ អនក្រ ប.ក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ពន្ធរដ្ឋបាលស្រុក

ច្បាប់

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ២០០៨
- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ២០១៩
- ច្បាប់វិសោធនកម្មស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ២០១៧

សៀវភៅ

- សៀវភៅ នីតិរដ្ឋបាល គ្រូឧត្តមសិក្សាជាន់ខ្ពស់ ង៉ីយ ធឿន ២០១៧
- សៀវភៅ សហត្ថិភាពរដ្ឋបាលដែនដីនៃកម្ពុជា សាស្ត្រាចារ្យ ហៀង សាង ២០១៨
- សៀវភៅ ការគ្រប់គ្រងរដ្ឋបាលដែនដី សាស្ត្រាចារ្យ ហៀង សាង និងអនុបណ្ឌិត ប៉េង ឆុង ២០១២
- សៀវភៅ ប្រព័ន្ធរដ្ឋបាលកម្ពុជា គ្រូឧត្តមសិក្សាជាន់ខ្ពស់ ង៉ីយ ធឿន២០១៩
- សៀវភៅ អភិបាលកិច្ចល្អ (២០១០) ក្រសួងមហាផ្ទៃ
- សៀវភៅ នីតិរដ្ឋបាលទូទៅ សាស្ត្រាចារ្យ ហៀង សាង ២០១៧
- សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ សាស្ត្រាចារ្យ ពៅ សារឿន ២០១០
- សៀវភៅ ការគ្រប់គ្រងរដ្ឋបាលស្រុក ២០១៩
- សៀវភៅ ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ២០១៩
- សៀវភៅ ការគ្រប់គ្រងរដ្ឋបាលក្រុង ២០១៩
- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩
- និក្ខេបបទបណ្ឌិតវិទ្យាសាស្ត្រនយោបាយ ស្តីពីការវិវត្តនៃរដ្ឋបាលកម្ពុជា (១៩៩៣-២០០៨) សួង លាងហៃ ២០១០

អ៊ិនធើណែត


- Gillin, J. L. (១៩១៩). What is meant by democracy. The origin of democracy, ២៤(០៦), ៧០៤-៧១៤. ដកស្រង់ចេញពី https://www.jstor.org/stable/2764122
- រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា. http://national-assembly.org.kh/group-article/11

# កម្រងសំនួរ

នាងខ្ញុំឈ្មោះ **ហៀម ឈុនភីរម្យ** និង **អ៊ុំ មរកត** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី១៣ ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច បានរៀបចំនូវកម្រងសំនួរ មួយចំនួន ទៅកាន់ ឯកឧត្តម **ចាន់ សុធា** ជាអនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិកាដ្ឋាន គ.ជ.អ.ប ព្រមទាំងលោក **ជ័យ សម្បត្តិផល្លា** ជាប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីញ៉ាំងឱ្យការសិក្សាលើប្រធានបទ កាន់តែមានភាពសុក្រិត្យ និងជាក់ច្បាស់ឡើង។
សំណួរដែលបានឡើងរួមមានដូចខាងក្រោមៈ

I. តើហេតុអ្វីចាំបាច់ត្រូវមានកំណែទម្រង់ / សមាហរណកម្មថ្មី?
II. តើការិយាល័យនីមួយៗមានមានទំនួលខុសត្រូវចំពោះមុខអ្នកណា?
III. តើការរៀបចំមន្រ្តីក្នុងការិយាល័យនីមួយៗ ផ្អែកទៅលើកត្តាអ្វីខ្លះ? ចុះអ្នកដែលមិនបានរៀបចំចូលបម្រើការក្នុងការិយាល័យវិញ?
IV. បញ្ហាអ្វីខ្លះដែលកើតមានឡើងក្នុងពេលកំណែទម្រង់?
V. តើមានដំណោះស្រាយអ្វី ខ្លះដែលលេខាធិការដ្ឋាន គ.ជ.អ.ប បានលើកឡើងដើម្បីកាត់បន្ថយបញ្ហាខាងលើ?
VI. ចូរធ្វើការអត្ថាធិប្បាយ អំពីកំណែទម្រង់ការិយាល័យជំនាញ? តើមានភាពខុសគ្នាអ្វីខ្លះ?
VII. ហេតុអ្វីបានជាមានករណីលើកលែងចំពោះក្រុងបាត់ដំបង ខេត្តបាត់ដំបង ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ក្រុង ស្រុក ខណ្ឌ?
VIII. តើរដ្ឋាភិបាលមានចក្ខុវិស័យនាពេលអនាគត បែបណាចំពោះកំណែទម្រង់នេះ?


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
លេខ..៦២៧.....ស.ភ.ន.វ.ស

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន**
**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**កម្មវត្ថុ៖** សំណើសុំអនុញ្ញាតឱ្យនិស្សិតចំនួន០២រូប ចុះស្រាវជ្រាវឯកសារ។

**យោង៖** សំណើរបស់សាមីនិស្សិតចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន ឯកឧត្តម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន មេត្តាជ្រាបថា៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបាន និងកំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ។ អំឡុងពេលសិក្សាឆ្នាំបញ្ចប់ និស្សិតយើងខ្ញុំចំនួន០២រូប ដូចមានបញ្ជីរាយនាមជូនភ្ជាប់មកជាមួយនេះ ត្រូវចុះស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារមួយចំនួនដែលទាក់ទងនឹងប្រធានបទស្តីពី «យន្តការថ្មីក្នុងការគ្រប់គ្រងរដ្ឋបាលដែនដី (ក្រុង ស្រុក ខណ្ឌ)» នៅគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចាប់ពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ ដើម្បីសរសេរសារណា និងការពារបញ្ចប់ការសិក្សារបស់ខ្លួន។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើខ្ញុំ សូម ឯកឧត្តម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន មេត្តាពិនិត្យលទ្ធភាពអនុញ្ញាតឱ្យនិស្សិតយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយសេចក្តីអនុគ្រោះ។

សូម ឯកឧត្តម មេត្តាទទួលនូវគោរវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ថ្ងៃសុក្រ ៧ រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០
**សាកលវិទ្យាធិការ**

**បណ្ឌិត លុយ ចណ្ណា**

15/06/2020

Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Cambodia.
P.O. Box 842, Tel: (855) 23 214 703, Fax: (855)23 214 953, E-mail: rector@rule.edu.kh,website: www.rule.edu.kh

លិខិតអនុញ្ញាតចុះកម្មសិក្សា



ការផ្តល់អនុសាសន៍របស់ឯកឧត្តម ចាន់ សុធា អនុរដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ
និងជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០



កិច្ចសម្ភាសន៍ជាមួយ លោក ជ័យ សម្បត្តិផល្លា ដែលជាប្រធានអង្គភាពវិភាគ
និងអភិវឌ្ឍន៍គោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៨៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**មាត្រា ៨.-**

ក្រសួងមហាផ្ទៃមានតួនាទី ភារកិច្ចដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល គាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃរដ្ឋបាលក្រុង ដើម្បីជានាឱ្យរដ្ឋបាលក្រុងគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងាររបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា និងអនុក្រឹត្យនេះ។

## ជំពូកទី៣

## ការបង្កើត តួនាទី ភារកិច្ច និងរបៀបរបបការងារនៃការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលក្រុង

### ផ្នែកទី១

### ការបង្កើតការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលក្រុង

**មាត្រា ៩.-**

រដ្ឋបាលក្រុងនីមួយៗត្រូវមានការិយាល័យ និងអង្គភាពមួយចំនួនជាចំណុះដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម
- ការិយាល័យគ្រប់គ្រងធនធានមនុស្ស
- ការិយាល័យផែនការ និងគាំទ្រសង្កាត់
- ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង
- ការិយាល័យលេខាធិការក្រុមប្រឹក្សា
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ
- ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម
- ការិយាល័យច្រកចេញចូលតែមួយ។

**មាត្រា ១០.-**

អង្គការលេខរបស់រដ្ឋបាលក្រុងមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា ១១.-**

ការិយាល័យ និងអង្គភាពនីមួយៗចំណុះរដ្ឋបាលក្រុងត្រូវដឹកនាំដោយប្រធានមួយ(០១)រូប និងមានអនុប្រធានយ៉ាងច្រើនចំនួនពីរ(០២)រូបជាជំនួយការ។

ការតែងតាំងប្រធាន និងអនុប្រធានការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលក្រុងត្រូវអនុវត្ត

គ.ជ.អ.ប. ត្រូវរៀបចំផែនការសកម្មភាព និងថវិកា ដោយកំណត់អំពីក្របខ័ណ្ឌពេលវេលាជាក់លាក់ និងក្រសួង ស្ថាប័នទទួលខុសត្រូវច្បាស់លាស់ ដើម្បីរៀបចំ និងអនុវត្តកិច្ចការចាំបាច់នានាដូចបានកំណត់ក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ។

**មាត្រា ៧១.-**

ការិយាល័យ និងអង្គភាពជំនាញពាក់ព័ន្ធនានារបស់ក្រសួង ស្ថាប័នដែលមាននៅថ្នាក់ក្រុងត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុងតាមការកំណត់ដូចខាងក្រោម៖

- ផ្ទេរការិយាល័យអប់រំ យុវជន និងកីឡានៃក្រសួងអប់រំ យុវជន និងកីឡានៅថ្នាក់ក្រុងមកជាការិយាល័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលក្រុង
- ផ្ទេរការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅថ្នាក់ក្រុងមកជាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលរបស់រដ្ឋបាលក្រុង
- ការិយាល័យព័ត៌មាននៃក្រសួងព័ត៌មានត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង
- ការិយាល័យផែនការស្ថិតិនៃក្រសួងផែនការត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យផែនការ និងគាំទ្រសង្កាត់របស់រដ្ឋបាលក្រុង
- មណ្ឌលសេវាកម្មយុត្តិធម៌នៃក្រសួងយុត្តិធម៌ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានរបស់រដ្ឋបាលក្រុង
- ការិយាល័យសាធារណការនិងដឹកជញ្ជូននៃក្រសួងសាធារណការ និងដឹកជញ្ជូន និងការិយាល័យបរិស្ថាននៃក្រសួងបរិស្ថានត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈរបស់រដ្ឋបាលក្រុង
- ការិយាល័យពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ការិយាល័យអភិវឌ្ឍន៍ជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ ការិយាល័យកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការិយាល័យឧស្សាហកម្មនិងសិប្បកម្មនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម ការិយាល័យរ៉ែនិងថាមពលនៃក្រសួងរ៉ែនិងថាមពល ការិយាល័យទេសចរណ៍នៃក្រសួងទេសចរណ៍ ការិយាល័យធនធានទឹកនិងឧតុនិយមនៃក្រសួងធនធានទឹកនិងឧតុនិយម និងការិយាល័យប្រៃសណីយ៍និងទូរគមនាគមន៍នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍របស់រដ្ឋបាលក្រុង
- ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការិយាល័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ការិយាល័យកិច្ចការនារីនៃក្រសួងកិច្ចការនារី ការិយាល័យវប្បធម៌

និងវិចិត្រសិល្បៈនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងការិយាល័យធម្មការនិងសាសនានៃក្រសួងធម្មការនិងសាសនា ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមរបស់រដ្ឋបាលក្រុង។

**មាត្រា ៧២.-**

ការិយាល័យ អង្គភាពនានារបស់រដ្ឋបាលក្រុងបច្ចុប្បន្នត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុងតាមការកំណត់ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ និងឬការិយាល័យគ្រប់គ្រងធនធានមនុស្ស និងឬការិយាល័យលេខាធិការក្រុមប្រឹក្សានៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង
- ការិយាល័យអភិវឌ្ឍន៍ក្រុងត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន និងឬការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍ និងឬការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម និងឬការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យបរិស្ថាននិងសណ្តាប់ធ្នាប់សាធារណៈនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង
- ការិយាល័យផែនការ និងគាំទ្រសង្កាត់ត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យផែនការ និងគាំទ្រសង្កាត់នៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង
- អង្គភាពលទ្ធកម្មត្រូវធ្វើសមាហរណកម្មទៅក្នុងអង្គភាពលទ្ធកម្មនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង
- ការិយាល័យច្រកចេញចូលតែមួយត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យច្រកចេញចូលតែមួយនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង
- ការិយាល័យរៀបចំសោភ័ណ្ឌភាព និងគ្រប់គ្រងកាកសំណល់នៃរដ្ឋបាលក្រុងបាត់ដំបងត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុងបាត់ដំបង។

**មាត្រា ៧៣.-**

បុគ្គលិក ទ្រព្យសម្បត្តិ និងឯកសារលិខិតស្នាមនានានៃការិយាល័យ និងអង្គភាពនានាដែលត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ត្រូវផ្ទេរមកក្រោមការគ្រប់គ្រងរបស់ការិយាល័យឬអង្គភាពថ្មីដូចមានកំណត់ក្នុងមាត្រា៧១ និងមាត្រា៧២នៃអនុក្រឹត្យនេះ។

រដ្ឋបាលខេត្តត្រូវសម្របសម្រួល និងគាំទ្រដល់ការផ្ទេរជាក់ស្តែងនូវបុគ្គលិក ទ្រព្យសម្បត្តិ និងឯកសារលិខិតស្នាមនានាដូចបានកំណត់ក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ។

**មាត្រា ៧៤.-**

បុគ្គលិកដែលបានផ្ទេរមកបំពេញការងារនៅរដ្ឋបាលក្រុងត្រូវ៖

- ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុងស្របតាមគោលការណ៍ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជាធរមាន
- បន្តស្ថិតនៅក្នុងក្របខ័ណ្ឌដែលសាមីខ្លួនបានតាំងស៊ប់មុនពេលផ្ទេរមករដ្ឋបាលក្រុង រហូតដល់មានការរៀបចំឡើងវិញស្របតាមមាត្រា១៣នៃអនុក្រឹត្យនេះ
- មានក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗមិនទាបជាងក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗដែលបុគ្គលិកទាំងនោះធ្លាប់បានទទួលមុនពេលផ្ទេរឡើយ។

**មាត្រា ៧៥.-**

ការផ្ទេរបុគ្គលិកក្នុងដំណាក់កាលនៃការធ្វើសមាហរណកម្មការិយាល័យជំនាញនានាទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុងត្រូវផ្អែកតាមគោលការណ៍ដូចខាងក្រោម៖

- ប្រធាន និងអនុប្រធានការិយាល័យអប់រំ យុវជននិងកីឡា និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលដែលកំពុងកាន់មុខតំណែងបច្ចុប្បន្នត្រូវបន្តតែងតាំងជាប្រធាន និងអនុប្រធាននៃការិយាល័យទាំងពីរនេះ។ ក្នុងករណីដែលការិយាល័យណាមួយពុំទាន់មានប្រធាន ឬអនុប្រធានការិយាល័យ ការសម្រេចតែងតាំងប្រធាន ឬអនុប្រធានការិយាល័យនោះត្រូវផ្អែកតាមលក្ខខណ្ឌដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ
- ប្រធានការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍ ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម និងការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាននិងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានតែងតាំងដោយជ្រើសរើសបេក្ខភាពចេញពីចំណោមប្រធានការិយាល័យជំនាញនានា និងឬប្រធានការិយាល័យនៃរដ្ឋបាលក្រុងដែលកំពុងកាន់មុខតំណែងបច្ចុប្បន្នដែលត្រូវបានធ្វើសមាហរណកម្មទៅក្នុងការិយាល័យទាំងនេះ។ ប្រធានការិយាល័យជំនាញទាំងឡាយណាដែលពុំត្រូវបានតែងតាំងជាប្រធានការិយាល័យក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្មីត្រូវតែងតាំងជាអនុប្រធានការិយាល័យចង្កោមវិស័យនោះ។ អនុប្រធានការិយាល័យជំនាញទាំងអស់នៃការិយាល័យដែលត្រូវបានធ្វើសមាហរណកម្មត្រូវតែងតាំងជាអនុប្រធានការិយាល័យចង្កោមវិស័យនោះ
- ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យច្រកចេញចូលតែមួយ និងអង្គភាពលទ្ធកម្មនៃរដ្ឋបាលក្រុងបច្ចុប្បន្នត្រូវបន្តរក្សាមុខតំណែងជាប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យច្រកចេញចូលតែមួយ និងអង្គភាពលទ្ធកម្មនៃរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលក្រុង
- ប្រធាន និងអនុប្រធានការិយាល័យផែនការ និងគាំទ្រសង្កាត់នៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុងត្រូវជ្រើសរើសចេញពីប្រធាន និងអនុប្រធានការិយាល័យផែនការ និងគាំទ្រសង្កាត់បច្ចុប្បន្ន និងការិយាល័យផែនការស្ថិតិនៃក្រសួងផែនការ

- ការរៀបចំមុខតំណែងប្រធាន និងអនុប្រធាននៃការិយាល័យផ្សេងទៀតក្រៅពីការិយាល័យ និងអង្គភាពដូចបានកំណត់ក្នុងចំណុចត្រទាំង៤ខាងលើនៃមាត្រានេះត្រូវជ្រើសរើសចេញពីប្រធាន ឬអនុប្រធានការិយាល័យនានាដែលត្រូវបានធ្វើសមាហរណកម្មបញ្ចូលមកក្នុងរចនាសម្ព័ន្ធថ្មី។ ការរៀបចំមុខតំណែងទាំងនេះត្រូវផ្អែកលើសមត្ថភាព ចំណេះដឹង ជំនាញ និងបទពិសោធន៍ការងារ
- បុគ្គលិកដែលត្រូវបានផ្ទេរពីការិយាល័យជំនាញនានាត្រូវរៀបចំបញ្ចូលទៅក្នុងការិយាល័យដែលពាក់ព័ន្ធនឹងវិស័យជំនាញរបស់ខ្លួន
- ក្នុងករណីមុខងារនៃវិស័យណាមួយដែលបានផ្ទេរមក ហើយពុំមានបុគ្គលិកត្រូវបានផ្ទេរមកជាមួយ រដ្ឋបាលក្រុងត្រូវរៀបចំឱ្យមានបុគ្គលិកទទួលខុសត្រូវលើមុខងារនោះ។ ក្នុងករណីនេះ ក្រសួង ស្ថាប័ននៃវិស័យជំនាញត្រូវផ្តល់ការបណ្តុះបណ្តាលជាបន្ទាន់ដល់មន្ត្រីទាំងនោះ។

**មាត្រា ៧៦.-**

គ.ជ.អ.ប. ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវសម្រេចអំពីការរៀបចំផ្ទេរបុគ្គលិក និងមុខតំណែងគ្រប់គ្រងតាមការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលក្រុងក្នុងដំណាក់កាលសមាហរណកម្មនេះ។

ក្រោយពេលធ្វើសមាហរណកម្ម ការតែងតាំង និងការបញ្ចប់មុខតំណែងនានានៃការិយាល័យ និងអង្គភាពចំណុះរដ្ឋបាលក្រុងត្រូវអនុវត្តតាមគោលការណ៍ នីតិវិធី និងបែបបទនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជាធរមាន។

គ.ជ.អ.ប. អាចបង្កើតក្រុមការងារអន្តរក្រសួងមួយដែលមានសមាសភាពមកពីក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាដើម្បីជួយដល់ គ.ជ.អ.ប. ក្នុងការរៀបចំកិច្ចការទាំងនេះ។

**មាត្រា ៧៧.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គ.ជ.អ.ប. ត្រូវកំណត់ទំហំធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ដើម្បីផ្ទេរទៅឱ្យរដ្ឋបាលក្រុងសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនានាដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះចាប់ពីខែមករា ឆ្នាំ២០២០តទៅ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា ៧៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។



k

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៨៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**មាត្រា ៥.-**

រដ្ឋបាលខណ្ឌមានកាតព្វកិច្ចគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានីភ្នំពេញ ដោយផ្អែកតាមគោលការណ៍ នីតិវិធី ស្តង់ដាសេវាដែលបានកំណត់ និងធនធានដែលបានផ្ទេរមានភ្ជាប់លក្ខខណ្ឌ ព្រមទាំងអាចប្រើប្រាស់ធនធានដែលគៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត ដើម្បីអនុវត្តមុខងារទាំងនោះឱ្យកាន់តែមានប្រសិទ្ធភាព។

គោលការណ៍ នីតិវិធី និងស្តង់ដាសេវាសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលត្រូវបានធ្វើប្រតិភូកម្ម ត្រូវកំណត់ដោយក្រសួង ស្ថាប័ននៃវិស័យនីមួយៗ ឬដោយរដ្ឋបាលរាជធានីភ្នំពេញ។

**មាត្រា ៦.-**

រដ្ឋបាលរាជធានីត្រូវពិនិត្យមើលឡើងវិញនូវមុខងារនានារបស់ខ្លួន ដើម្បីបន្តផ្ទេរមុខងារសមស្របទៅឱ្យរដ្ឋបាលខណ្ឌ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣

## ការបង្កើត តួនាទី ភារកិច្ច និងរបៀបរបបការងារនៃការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលខណ្ឌ

### ផ្នែកទី១

### ការបង្កើតការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលខណ្ឌ

**មាត្រា ៧.-**

រដ្ឋបាលខណ្ឌនីមួយៗត្រូវមានការិយាល័យ និងអង្គភាពមួយចំនួនជាចំណុះដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងបុគ្គលិក
- ការិយាល័យផែនការ និងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម
- ការិយាល័យលេខាធិការក្រុមប្រឹក្សា
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ
- ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម
- ការិយាល័យច្រកចេញចូលតែមួយ។

**មាត្រា ៨.-**

អង្គការលេខរបស់រដ្ឋបាលខណ្ឌមានកំណត់នៅក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

**មាត្រា ៥៣.-**

ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមានរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ រដ្ឋបាលខណ្ឌ និងការិយាល័យជំនាញនានានៅថ្នាក់ខណ្ឌត្រូវបន្តអនុវត្តតាមរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនាពេលបច្ចុប្បន្ន។

**មាត្រា ៥៤.-**

គ.ជ.អ.ប. ត្រូវដឹកនាំ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី និងរដ្ឋបាលខណ្ឌ ក្នុងការរៀបចំនូវកិច្ចការនានាពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ បុគ្គលិក ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងកិច្ចការចាំបាច់ផ្សេងទៀត ដើម្បីធានាឱ្យរដ្ឋបាលខណ្ឌអាចចាប់ផ្តើមអនុវត្តនូវមុខងារ និងតួនាទី ភារកិច្ចរបស់ខ្លួនតាមរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងដែលបានកំណត់ក្នុងអនុក្រឹត្យនេះចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០តទៅ។

គ.ជ.អ.ប. ត្រូវរៀបចំផែនការសកម្មភាព និងថវិកាដោយកំណត់អំពីក្របខ័ណ្ឌពេលវេលាជាក់លាក់ និងក្រសួង ស្ថាប័នទទួលខុសត្រូវច្បាស់លាស់ ដើម្បីរៀបចំ និងអនុវត្តកិច្ចការចាំបាច់នានាដូចបានកំណត់ក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ។

**មាត្រា ៥៥.-**

ការិយាល័យ និងអង្គភាពជំនាញពាក់ព័ន្ធនានារបស់ក្រសួង ស្ថាប័នដែលមាននៅថ្នាក់ខណ្ឌត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលខណ្ឌតាមការកំណត់ដូចខាងក្រោម៖

- ផ្ទេរការិយាល័យអប់រំ យុវជន និងកីឡានៃក្រសួងអប់រំ យុវជន និងកីឡានៅថ្នាក់ខណ្ឌមកជាការិយាល័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលខណ្ឌ
- ផ្ទេរការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅថ្នាក់ខណ្ឌមកជាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលរបស់រដ្ឋបាលខណ្ឌ
- ការិយាល័យព័ត៌មាននៃក្រសួងព័ត៌មានត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យរដ្ឋបាលនិងបុគ្គលិករបស់រដ្ឋបាលខណ្ឌ
- ការិយាល័យផែនការស្ថិតិនៃក្រសួងផែនការត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យផែនការ និងហិរញ្ញវត្ថុរបស់រដ្ឋបាលខណ្ឌ
- មណ្ឌលសេវាកម្មយុត្តិធម៌នៃក្រសួងយុត្តិធម៌ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានរបស់រដ្ឋបាលខណ្ឌ
- ការិយាល័យសាធារណការនិងដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន និងការិយាល័យបរិស្ថាននៃក្រសួងបរិស្ថានត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈរបស់រដ្ឋបាលខណ្ឌ
- ការិយាល័យពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ការិយាល័យអភិវឌ្ឍន៍ជនបទនៃក្រសួង

អភិវឌ្ឍន៍ជនបទ ការិយាល័យកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ការិយាល័យឧស្សាហកម្មនិងសិប្បកម្មនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម ការិយាល័យរ៉ែនិងថាមពលនៃក្រសួងរ៉ែនិងថាមពល ការិយាល័យទេសចរណ៍នៃក្រសួងទេសចរណ៍ ការិយាល័យធនធានទឹកនិងឧតុនិយមនៃក្រសួងធនធានទឹកនិងឧតុនិយម និងការិយាល័យប្រៃសណីយ៍និងទូរគមនាគមន៍នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍របស់រដ្ឋបាលខណ្ឌ

- ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការិយាល័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ការិយាល័យកិច្ចការនារីនៃក្រសួងកិច្ចការនារី ការិយាល័យវប្បធម៌និងវិចិត្រសិល្បៈនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងការិយាល័យធម្មការនិងសាសនានៃក្រសួងធម្មការនិងសាសនា ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមរបស់រដ្ឋបាលខណ្ឌ។

**មាត្រា ៥៦.-**

ការិយាល័យ អង្គភាពនានារបស់រដ្ឋបាលខណ្ឌបច្ចុប្បន្នត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលខណ្ឌតាមការកំណត់ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យរដ្ឋបាលនិងបុគ្គលិក និងឬការិយាល័យលេខាធិការក្រុមប្រឹក្សា និងឬការិយាល័យផែនការនិងហិរញ្ញវត្ថុនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលខណ្ឌ
- ការិយាល័យអន្តរវិស័យត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យនីតិកម្មនិងសម្រុះសម្រួលវិវាទមូលដ្ឋាន និងឬការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍ និងឬការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម និងឬការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលខណ្ឌ
- ការិយាល័យផែនការ និងអភិវឌ្ឍន៍ត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យផែនការ និងហិរញ្ញវត្ថុនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលខណ្ឌ
- អង្គភាពលទ្ធកម្មត្រូវធ្វើសមាហរណកម្មទៅក្នុងអង្គភាពលទ្ធកម្មនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលខណ្ឌ
- ការិយាល័យច្រកចេញចូលតែមួយត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យច្រកចេញចូលតែមួយនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលខណ្ឌ។

**មាត្រា ៥៧.-**

បុគ្គលិក ទ្រព្យសម្បត្តិ និងឯកសារលិខិតស្នាមនានានៃការិយាល័យ និងអង្គភាពនានាដែលត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលខណ្ឌ ត្រូវផ្ទេរមកក្រោមការគ្រប់គ្រងរបស់ការិយាល័យឬអង្គភាពថ្មីដូចមានកំណត់ក្នុងមាត្រា៥៥ និងមាត្រា៥៦នៃអនុក្រឹត្យនេះ។

រដ្ឋបាលរាជធានីត្រូវសម្របសម្រួល និងគាំទ្រដល់ការផ្ទេរជាក់ស្តែងនូវបុគ្គលិក ទ្រព្យសម្បត្តិ និងឯកសារលិខិតស្នាមនានាដូចបានកំណត់ក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ។

**មាត្រា ៥៨.-**

បុគ្គលិកដែលបានផ្ទេរមកបំពេញការងារនៅរដ្ឋបាលខណ្ឌសាមីនីមួយៗត្រូវ៖

- ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានីភ្នំពេញស្របតាមគោលការណ៍ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជាធរមាន
- បន្តស្ថិតនៅក្នុងក្របខ័ណ្ឌដែលសាមីខ្លួនបានតាំងស៊ប់មុនពេលផ្ទេរមករដ្ឋបាលខណ្ឌ រហូតដល់មានការរៀបចំឡើងវិញស្របតាមមាត្រា១១នៃអនុក្រឹត្យនេះ
- មានក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗមិនទាបជាងក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗដែលបុគ្គលិកទាំងនោះធ្លាប់បានទទួលមុនពេលផ្ទេរឡើយ។

**មាត្រា ៥៩.-**

ការផ្ទេរបុគ្គលិកក្នុងដំណាក់កាលនៃការធ្វើសមាហរណកម្មការិយាល័យជំនាញនានាទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខណ្ឌត្រូវផ្អែកតាមគោលការណ៍ដូចខាងក្រោម៖

- ប្រធាន និងអនុប្រធានការិយាល័យអប់រំ យុវជននិងកីឡា និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលដែលកំពុងកាន់មុខតំណែងបច្ចុប្បន្នត្រូវបន្តតែងតាំងជាប្រធាន និងអនុប្រធាននៃការិយាល័យទាំងពីរនេះ។ ក្នុងករណីដែលការិយាល័យណាមួយពុំទាន់មានប្រធាន ឬអនុប្រធានការិយាល័យ ការសម្រេចតែងតាំងប្រធាន ឬអនុប្រធានការិយាល័យនោះត្រូវផ្អែកតាមលក្ខខណ្ឌដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ
- ប្រធានការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍ ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម និងការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាននិងសណ្តាប់ធ្នាប់សាធារណៈត្រូវបានតែងតាំងដោយជ្រើសរើសបេក្ខភាពចេញពីចំណោមប្រធានការិយាល័យជំនាញនានា និងឬប្រធានការិយាល័យនៃរដ្ឋបាលខណ្ឌដែលកំពុងកាន់មុខតំណែងបច្ចុប្បន្នដែលត្រូវបានធ្វើសមាហរណកម្មទៅក្នុងការិយាល័យទាំងនេះ។ ប្រធានការិយាល័យជំនាញទាំងឡាយណាដែលពុំត្រូវបានតែងតាំងជាប្រធានការិយាល័យក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្មីត្រូវតែងតាំងជាអនុប្រធានការិយាល័យចង្កោមវិស័យនោះ។ អនុប្រធានការិយាល័យជំនាញទាំងអស់នៃការិយាល័យ ដែលត្រូវបានធ្វើសមាហរណកម្មត្រូវតែងតាំងជាអនុប្រធានការិយាល័យចង្កោមវិស័យនោះ
- ប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្ម និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលខណ្ឌបច្ចុប្បន្នត្រូវបន្តរក្សាមុខតំណែងជាប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្ម និងការិយាល័យច្រកចេញចូលតែមួយក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលខណ្ឌ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៨៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**មាត្រា ៨.-**

ក្រសួងមហាផ្ទៃមានតួនាទី ភារកិច្ចដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល គាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃរដ្ឋបាលស្រុកដើម្បីធានាឱ្យរដ្ឋបាលស្រុកគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងាររបស់ខ្លួនបានត្រឹមត្រូវ ស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា និងអនុក្រឹត្យនេះ។

## ជំពូកទី៣

## ការបង្កើត តួនាទី ភារកិច្ច និងរបៀបរបបការងារនៃការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុក

### ផ្នែកទី១

### ការបង្កើតការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុក

**មាត្រា ៩.-**

រដ្ឋបាលស្រុកនីមួយៗត្រូវមានការិយាល័យ និងអង្គភាពមួយចំនួនជាចំណុះដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម
- ការិយាល័យគ្រប់គ្រងធនធានមនុស្ស
- ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់
- ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង
- ការិយាល័យលេខាធិការក្រុមប្រឹក្សា
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន
- ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ការិយាល័យសង្គមកិច្ច និងសុខមាលភាពសង្គម
- ការិយាល័យច្រកចេញចូលតែមួយ។

**មាត្រា ១០.-**

អង្គការលេខរបស់រដ្ឋបាលស្រុកមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា ១១.-**

ការិយាល័យ និងអង្គភាពនីមួយៗចំណុះរដ្ឋបាលស្រុកត្រូវដឹកនាំដោយប្រធានមួយ (០១)រូប និងមានអនុប្រធានយ៉ាងច្រើនចំនួនពីរ (០២)រូបជាជំនួយការ។

ការតែងតាំងប្រធាន និងអនុប្រធានការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុកត្រូវអនុវត្ត

**មាត្រា ៧០.-**

គ.ជ.អ.ប. ត្រូវដឹកនាំ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំនូវកិច្ចការនានាពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ បុគ្គលិក ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងកិច្ចការចាំបាច់ផ្សេងទៀត ដើម្បីធានាឱ្យរដ្ឋបាលស្រុកអាចចាប់ផ្តើមអនុវត្តនូវមុខងារ និងតួនាទី ភារកិច្ចរបស់ខ្លួនតាមរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងដែលបានកំណត់ក្នុងអនុក្រឹត្យនេះចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០តទៅ។

គ.ជ.អ.ប. ត្រូវរៀបចំផែនការសកម្មភាព និងថវិកា ដោយកំណត់អំពីក្របខ័ណ្ឌពេលវេលាជាក់លាក់ និងក្រសួង ស្ថាប័នទទួលខុសត្រូវច្បាស់លាស់ ដើម្បីរៀបចំ និងអនុវត្តកិច្ចការចាំបាច់នានាដូចបានកំណត់ក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ។

**មាត្រា ៧១.-**

ការិយាល័យ និងអង្គភាពជំនាញពាក់ព័ន្ធនានារបស់ក្រសួង ស្ថាប័នដែលមាននៅថ្នាក់ស្រុកត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុកតាមការកំណត់ដូចខាងក្រោម៖

- ផ្ទេរការិយាល័យអប់រំ យុវជន និងកីឡានៃក្រសួងអប់រំ យុវជន និងកីឡានៅថ្នាក់ស្រុកមកជាការិយាល័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលស្រុក
- ផ្ទេរការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅថ្នាក់ស្រុកមកជាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលរបស់រដ្ឋបាលស្រុក
- ការិយាល័យព័ត៌មាននៃក្រសួងព័ត៌មានត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុរបស់រដ្ឋបាលស្រុក
- ការិយាល័យផែនការ ស្ថិតិនៃក្រសួងផែនការត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់របស់រដ្ឋបាលស្រុក
- មណ្ឌលសេវាកម្មយុត្តិធម៌នៃក្រសួងយុត្តិធម៌ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានរបស់រដ្ឋបាលស្រុក
- ការិយាល័យបរិស្ថាននៃក្រសួងបរិស្ថាន ការិយាល័យកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យធនធានទឹកនិងឧតុនិយមនៃក្រសួងធនធានទឹកនិងឧតុនិយម ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថានរបស់រដ្ឋបាលស្រុក
- ការិយាល័យសាធារណការនិងដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន ការិយាល័យពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ការិយាល័យអភិវឌ្ឍន៍ជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ ការិយាល័យឧស្សាហកម្មនិងសិប្បកម្មនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម ការិយាល័យរ៉ែ និងថាមពលនៃក្រសួងរ៉ែនិងថាមពល ការិយាល័យទេសចរណ៍នៃក្រសួងទេសចរណ៍ និង

ការិយាល័យប្រៃសណីយ៍និងទូរគមនាគមន៍នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍របស់រដ្ឋបាលស្រុក

- ការិយាល័យសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទានៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការិយាល័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ការិយាល័យកិច្ចការនារីនៃក្រសួងកិច្ចការនារី ការិយាល័យវប្បធម៌និងវិចិត្រសិល្បៈនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងការិយាល័យធម្មការនិងសាសនានៃក្រសួងធម្មការនិងសាសនា ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមរបស់រដ្ឋបាលស្រុក។

**មាត្រា ៧២.-**

ការិយាល័យ អង្គភាពនានារបស់រដ្ឋបាលស្រុកបច្ចុប្បន្នត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុកតាមការកំណត់ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ និងឬការិយាល័យគ្រប់គ្រងធនធានមនុស្ស និងឬការិយាល័យលេខាធិការក្រុមប្រឹក្សានៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុក
- ការិយាល័យអន្តរវិស័យត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យនីតិកម្មនិងសម្រុះសម្រួលវិវាទមូលដ្ឋាន និងឬការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍ និងឬការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម និងឬការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាននៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុក
- ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យផែនការនិងគាំទ្រឃុំ សង្កាត់នៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុក
- អង្គភាពលទ្ធកម្មត្រូវធ្វើសមាហរណកម្មទៅក្នុងអង្គភាពលទ្ធកម្មនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុក
- ការិយាល័យច្រកចេញចូលតែមួយត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យច្រកចេញចូលតែមួយនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុក។

**មាត្រា ៧៣.-**

បុគ្គលិក ទ្រព្យសម្បត្តិ និងឯកសារលិខិតស្នាមនានានៃការិយាល័យ និងអង្គភាពនានាដែលត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលស្រុក ត្រូវផ្ទេរមកក្រោមការគ្រប់គ្រងរបស់ការិយាល័យឬអង្គភាពថ្មីដូចមានកំណត់ក្នុងមាត្រា៧១ និងមាត្រា៧២នៃអនុក្រឹត្យនេះ។

រដ្ឋបាលខេត្តត្រូវសម្របសម្រួល និងគាំទ្រដល់ការផ្ទេរជាក់ស្តែងនូវបុគ្គលិក ទ្រព្យសម្បត្តិ និងឯកសារលិខិតស្នាមនានាដូចបានកំណត់ក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ។

**មាត្រា ៧៤.-**

បុគ្គលិកដែលបានផ្ទេរមកបំពេញការងារនៅរដ្ឋបាលស្រុកត្រូវ ៖

- ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលស្រុកស្របតាមគោលការណ៍ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជាធរមាន
- បន្តស្ថិតនៅក្នុងក្របខ័ណ្ឌដែលសាមីខ្លួនបានតាំងស៊ប់មុនពេលផ្ទេរមករដ្ឋបាលស្រុករហូតដល់មានការរៀបចំឡើងវិញស្របតាមមាត្រា១៣នៃអនុក្រឹត្យនេះ
- មានក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗមិនទាបជាងក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗដែលបុគ្គលិកទាំងនោះធ្លាប់បានទទួលមុនពេលផ្ទេរឡើយ។

**មាត្រា ៧៥.-**

ការផ្ទេរបុគ្គលិកក្នុងដំណាក់កាលនៃការធ្វើសមាហរណកម្មការិយាល័យជំនាញនានាទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលស្រុកត្រូវផ្អែកតាមគោលការណ៍ដូចខាងក្រោម ៖

- ប្រធាន និងអនុប្រធានការិយាល័យអប់រំ យុវជននិងកីឡា និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលដែលកំពុងកាន់មុខតំណែងបច្ចុប្បន្នត្រូវបន្តតែងតាំងជាប្រធាន និងអនុប្រធាននៃការិយាល័យទាំងពីរនេះ។ ក្នុងករណីដែលការិយាល័យណាមួយពុំទាន់មានប្រធាន ឬអនុប្រធានការិយាល័យ ការសម្រេចតែងតាំងប្រធាន ឬអនុប្រធានការិយាល័យនោះត្រូវផ្អែកតាមលក្ខខណ្ឌដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ
- ប្រធានការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍ ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម និងការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន ត្រូវបានតែងតាំងដោយជ្រើសរើសបេក្ខភាពចេញពីចំណោមប្រធានការិយាល័យជំនាញនានា និងឬប្រធានការិយាល័យនៃរដ្ឋបាលស្រុកដែលកំពុងកាន់មុខតំណែងបច្ចុប្បន្នដែលត្រូវបានធ្វើសមាហរណកម្មទៅក្នុងការិយាល័យទាំងនេះ។ ប្រធានការិយាល័យជំនាញទាំងឡាយណាដែលពុំត្រូវបានតែងតាំងជាប្រធានការិយាល័យក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្មី ត្រូវតែងតាំងជាអនុប្រធានការិយាល័យចង្កោមវិស័យនោះ។ អនុប្រធានការិយាល័យជំនាញទាំងអស់នៃការិយាល័យដែលត្រូវបានធ្វើសមាហរណកម្មត្រូវតែងតាំងជាអនុប្រធានការិយាល័យចង្កោមវិស័យនោះ
- ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យច្រកចេញចូលតែមួយ និងអង្គភាពលទ្ធកម្មនៃរដ្ឋបាលស្រុកបច្ចុប្បន្នត្រូវបន្តរក្សាមុខតំណែងជាប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យច្រកចេញចូលតែមួយ និងអង្គភាពលទ្ធកម្មនៃរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលស្រុក
- ប្រធាន និងអនុប្រធានការិយាល័យផែនការនិងគាំទ្រឃុំ សង្កាត់នៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុកត្រូវជ្រើសរើសចេញពីប្រធាន និងអនុប្រធានការិយាល័យផែនការនិងគាំទ្រឃុំ សង្កាត់បច្ចុប្បន្ន ឬការិយាល័យផែនការស្ថិតិនៃក្រសួងផែនការ



Ak

- ការរៀបចំមុខតំណែងប្រធាន និងអនុប្រធាននៃការិយាល័យផ្សេងទៀតក្រៅពីការិយាល័យ និងអង្គភាពដូចបានកំណត់ក្នុងចំណុចត្រេទាំង៤ខាងលើនៃមាត្រានេះត្រូវជ្រើសរើសចេញពីប្រធាន ឬអនុប្រធានការិយាល័យនានាដែលត្រូវបានធ្វើសមាហរណកម្មបញ្ចូលមកក្នុងរចនាសម្ព័ន្ធថ្មី។ ការរៀបចំមុខតំណែងទាំងនេះត្រូវផ្អែកលើសមត្ថភាព ចំណេះដឹង ជំនាញ និងបទពិសោធន៍ការងារ
- បុគ្គលិកដែលត្រូវបានផ្ទេរពីការិយាល័យជំនាញនានាត្រូវរៀបចំបញ្ចូលទៅក្នុងការិយាល័យដែលពាក់ព័ន្ធនឹងវិស័យជំនាញរបស់ខ្លួន
- ក្នុងករណីមុខងារនៃវិស័យណាមួយដែលបានផ្ទេរមក ហើយពុំមានបុគ្គលិកត្រូវបានផ្ទេរមកជាមួយ រដ្ឋបាលស្រុកត្រូវរៀបចំឱ្យមានបុគ្គលិកទទួលខុសត្រូវលើមុខងារនោះ។ ក្នុងករណីនេះ ក្រសួង ស្ថាប័ននៃវិស័យជំនាញត្រូវផ្តល់ការបណ្តុះបណ្តាលជាបន្ទាន់ដល់មន្ត្រីទាំងនោះ។

**មាត្រា ៧៦.-**

គ.ជ.អ.ប. ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវសម្រេចអំពីការរៀបចំផ្ទេរបុគ្គលិក និងមុខតំណែងគ្រប់គ្រងតាមការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុកក្នុងដំណាក់កាលសមាហរណកម្មនេះ។

ក្រោយពេលធ្វើសមាហរណកម្ម ការតែងតាំង និងការបញ្ចប់មុខតំណែងនានានៃការិយាល័យ និងអង្គភាពចំណុះរដ្ឋបាលស្រុកត្រូវអនុវត្តតាមគោលការណ៍ នីតិវិធី និងបែបបទនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជាធរមាន។

គ.ជ.អ.ប. អាចបង្កើតក្រុមការងារអន្តរក្រសួងមួយដែលមានសមាសភាពមកពីក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខាធិការដ្ឋានគ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីជួយដល់គ.ជ.អ.ប. ក្នុងការរៀបចំកិច្ចការទាំងនេះ។

**មាត្រា ៧៧.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គ.ជ.អ.ប. ត្រូវកំណត់ទំហំធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ដើម្បីផ្ទេរទៅឱ្យរដ្ឋបាលស្រុកសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនានាដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះចាប់ពីខែមករា ឆ្នាំ២០២០តទៅ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា ៧៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។